ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Nov-2011, 13:44
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## បើកសេចក្តីសន្និដ្ឋានចោទប្រកាន់

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក យ៉េត ចរិយា

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស

*(Mr. Jacques VERGES)*

លោក អាកទួរ វែកគែន

(Mr. Arthur VERCKEN)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ជេត វណ្ណលី

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JACQUIN)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ី សុវ៉ន

លោក សំ សុគង់

លោកស្រី នូស៊ីន សាការ៉ាទី

*(Ms. Nushin SARKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក ហ្សាក់ វែកហ្សេស | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អៀង សារី | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០២:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

កាលពីម្សិលមិញចុងម៉ោងមុននឹងផ្អាកកិច្ចដំណើរការនីតិវិធី មេធាវី អៀង សារី បានស្នើសុំឱ្យលោក អៀង សារី ធ្វើសេចក្តីប្រកាសរបស់ខ្លួន ហើយអង្គជំនុំជម្រះបានសម្រេចឱ្យ អៀង សារី ធ្វើបន្តធ្វើនៅព្រឹកនេះ។ ហេតុដូច្នេះ សូមអនុរក្សមន្ទីរឃុំឃាំងនាំជន-- លោក អៀង សារី ត្រឡប់ទៅ-- អញ្ជើញលោកមេធាវី សុន អរុណ មុន។

**លោក សុន អរុណ៖**

សូមអគុណលោកប្រធានពី កាលពីថ្ងៃចន្ទ ខ្ញុំបានបង្ហាញខ្លួនមេធាវីទើបតែបានស្បថ ធ្វើការសម្បថថ្មី លោក *អេនឌ្រូ អេណូហ្ស៊ី* ថ្ងៃនេះសូមតុលាការមេត្តាទទួលស្គាល់លោក *អេនឌ្រូ អេណូហ្ស៊ី* ថ្ងៃនេះផង ពីព្រោះអីពីថ្ងៃមុនលោកប្រធានថា រង់ចាំមើលឯកសារ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី ប៉ុន្តែនាពេលនេះមិនទាន់ចាំបាច់ទេ ដោយហេតុផលក្រៅពីមើលឯកសារអង្គជំនុំជម្រះត្រូវចេញដីកាសម្រេចទទួលស្គាល់គាត់ជាផ្លូវការ ដោយទៅរៀបចំនូវភាសាទាំងបីភាសាផងដែរ។ អ៊ីចឹង គឺយើងគិតថា មិនទាន់ប្រញាប់ពេកទេ ហើយយើងបានឱ្យមន្ត្រីច្បាប់កំពុងតែរៀបចំឱ្យហើយៗយើងមិនទាន់ចុះហត្ថលេខាលើដីកានោះទេ ដោយសារមូលហេតុពាក់ព័ន្ធទៅនឹងការបកប្រែភាសា ទាំងភាសាអង់គ្លេស និងភាសាបារាំង។

សូមអញ្ជើញលោក អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។ នៅព្រឹកនេះ លោក អៀង សារី មានសេចក្តីប្រកាសរបស់គាត់ ដែលគាត់អនុញ្ញាតឱ្យខ្ញុំបាទអានសេចក្តីប្រកាសរបស់គាត់នៅពេលនេះ សូមលោកប្រធានអនុញ្ញាតឱ្យខ្ញុំបាទអាន។ សេចក្តីប្រកាសនេះមាន

ដូចខ្ញុំជម្រាបម្សិលមិញមានប្រហែលជាមួយទំព័រកន្លះ ហើយអានប្រហែលពីរនាទីប៉ុណ្ណឹងទេ។ អ៊ីចឹងសូមលោកប្រធានអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៦:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានឯកភាពជាឯកច្ឆន្ទថា មិនអនុញ្ញាតឲ្យលោកមេធាវីថ្លែងនូវសេចក្ដីប្រកាសផ្ទាល់ខ្លួនរបស់គាត់ ជំនួសគាត់ទេ ពីព្រោះគាត់មានវត្តមាននៅទីនេះ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់ឈើរាងក្រចកសេះនៅមុខអង្គជំនុំជម្រះនេះ។ លោកអាចប្រើប្រាស់នូវរទេះរុញក្នុងករណីមានការលំបាកនៅក្នុងការនាំគាត់។

សូមអញ្ជើញលោក អៀង សារី!

**លោក អៀង សារី៖**

លោកចៅក្រមប្រធាន សូមគោរពលោក លោកស្រីចៅក្រមសមាជិក។ អរុណសួស្ដីលោកទាំងឡាយដែលមានវត្តមានថ្ងៃនេះ និងលោកអ្នកទាំងឡាយដែលកំពុងតាមដានកិច្ចដំណើរការនីតិវិធីនេះ។ នៅឆ្នាំ១៩៩៦ ខ្ញុំបាទបានទទួលព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស។ សហនាយករដ្ឋមន្ត្រីទាំងពីរនាកាលនោះ បានចរចាអំពីព្រះរាជក្រឹត្យលើកលែង និងអនុគ្រោះទោស ហើយក៏បានអនុម័តយល់ព្រមពីរដ្ឋសភាជាតិទៅលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះ រួចហើយអតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ នាពេលនោះ ទ្រង់ក៏បានចុះព្រះហត្ថលេខាយល់ព្រមលើ។ ហត់ណាស់ ខ្ញុំទៅមិនរួចទេ។ ខ្ញុំវាហត់ បេះដូងខ្ញុំទៅមិនរួចតែម្ដង។ ធ្វើម៉េចឥឡូវហ្នឹង មានឲ្យខ្ញុំឈប់ដេកសិន។

**ប្រធានអង្គជំនុំ៖**

ឥឡូវនៅប៉ុន្មានទៀត? ឥឡូវនៅប៉ុន្មានឃ្លាទៀត? លោកអាង ឧត្តម!

**លោក អាង ឧត្តម៖**

ដោយសារបញ្ហានេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានអានសេចក្ដីប្រកាសរបស់គាត់ជូនអង្គសវនាការជំនួសគាត់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអំមិញបានសម្រេចហើយ មិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ។ ចង់ស្តាប់ដោយសំឡេងគាត់ផ្ទាល់ ហើយគាត់បានបង្ហាញនូវការហត់។ ឥឡូវហ្នឹងយើងអនុញ្ញាតឲ្យគាត់សម្រាកបន្តិចទៅ ហើយនិងលទ្ធភាពដែលគាត់អាចបន្ត អានបន្តកម្រិតណាដែលអាចអានបាន ដើម្បីឲ្យចប់នូវសេចក្តីប្រកាសនោះ ដែលទំនងជាមានតែមួយទំព័រកន្លះប៉ុណ្ណោះ តាមការដែលផ្តល់ព័ត៌មានពីមេធាវី។

[០៩:១២:២១]

**លោក អៀង សារី៖**

ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះរួចហើយ អតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ នាពេលនោះ ទ្រង់ក៏បានចុះព្រះហត្ថលេខាយល់ព្រមលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះ។ ដោយឡែក ដោយផ្អែកលើយុទ្ធការ(?)នៃតុលាការពិសេសនេះ លោក លោកស្រីចៅក្រម បានសម្រេចថាព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះមិនអាចយកមកអនុគ្រោះបានឡើយ។

ថ្វីត្បិតខ្ញុំបាទមិនយល់ព្រមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្តី ក៏ខ្ញុំបាទនៅតែគោរពដល់អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសម្រេចអំពីរឿងនេះ ជាមួយនឹងសេចក្តីគោរពដ៏ជ្រាលជ្រៅនេះ ខ្ញុំបាទក៏មានសេចក្តីអំពល់ កង្វល់ បារម្ភ ជាខ្លាំងដែរ ដោយសារថាការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង មិនយល់ព្រមបង្អន់ដំណើរការនីតិវិធី រហូតដល់មានការសម្រេចពីបញ្ហានេះដោយអង្គជំនុំជម្រះតុលាការកំពូលរួចសិន។

[០៩:១៤:៣៧]

ខ្ញុំបាទមិនអាចគោរពសេចក្តីសម្រេចនេះបានឡើយ ជាពិសេសដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង គួរតែអាចបានចេញសេចក្តីសម្រេចរបស់ខ្លួនតាំងពីយូរណាស់មកហើយ គ្មានអ្វីរារាំងលោកចៅក្រមមិនឲ្យសម្រេចដូច្នេះឡើយ។ ខ្ញុំជាប់ឃុំអស់រយៈពេលជាងបួនឆ្នាំមកហើយ រង់ចាំការជំនុំជម្រះ។ ចាប់ពីនេះតទៅវានឹងចាប់ផ្តើមជាមួយនឹងបញ្ហាច្បាប់ដែលមានសារៈសំខាន់មួយ ដែលវាមិនទាន់ត្រូវបានដោះស្រាយបានពេញលេញនៅឡើយ។ ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានចាត់ការដោយត្រឹមត្រូវ ខ្ញុំយល់ឃើញថា ខ្ញុំបាទមិនគួរចូលរួមក្នុងការជំនុំជម្រះក្តីនេះទេ ដោយគួររង់ចាំរហូតដល់អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើ ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះសិន។ ប៉ុន្តែដោយសារសេចក្តីគោរពទៅលើស្ថាប័ននេះ ខ្ញុំបាទនឹងបន្តចូលរួមក្នុង

ដំណើរការនីតិវិធីនេះតទៅទៀតដូចដែលខ្ញុំបានតែងតែបាននិងកំពុងធ្វើដូច្នេះចាប់តាំងពីកាលដែលខ្ញុំបាទបានរងការចោទប្រកាន់ ត្រូវបានចាប់ខ្លួន និងត្រូវបាននាំខ្លួនមកឃុំឃាំងនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នេះម៉្លេះ។ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១, ហត្ថលេខា អៀង សារី។អស់ហើយខ្ញុំ។

[០៩:១៧:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោក អៀង សារី។ អនុរក្ស--

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមទោសលោកប្រធាន! លោក អៀង សារី បានអានពាក្យខ្លះខុស អនុញ្ញាតឲ្យខ្ញុំកែពាក្យដែលគាត់ចង់និយាយឬទេ? ឧទាហរណ៍ដូចពាក្យ "អនុវត្ត" នៅក្នុងកថាខណ្ឌទីបី គាត់អានទៅជា "អនុគ្រោះ" ហើយនៅក្នុងបន្ទាត់កថាខណ្ឌដដែល បន្ទាត់ទីប្រាំមួយ គាត់អាន "បង្អង់" គាត់ទៅជា "បង្អន់" អ៊ីចឹងសូមកែតម្រូវពាក្យនេះផងទាន។ បើមិនយល់ទាស់ទេ ខ្ញុំសូមអានឃ្លានេះជូនឲ្យត្រូវឡើងវិញជំនួសគាត់។

[០៩:១៨:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមអានឃ្លានេះឡើងវិញឲ្យត្រូវ។ ដោយផ្អែកលើយុត្តាធិការនៃតុលាការពិសេសនេះ លោកលោកស្រីចៅក្រមបានសម្រេចថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះមិនអាចយកមកអនុវត្តបានឡើយ។ ថ្វីត្បិតខ្ញុំបាទមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្ដីក៏ខ្ញុំបាទនៅតែគោរពដល់អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចអំពីរឿងនេះ។

**ប្រធានអង្គជំនុំ៖**

ចំណុចណាខ្លះដែលកែ។ អម្បាញ់មិញតែពីរចំណុចទេ?

**លោក អាង ឧត្តម៖**

ជាមួយនឹងសេចក្ដីគោរពដ៏ជ្រាលជ្រៅនេះ ខ្ញុំបាទក៏មានក្ដីអំពល់កង្វល់បារម្ភជាខ្លាំងដែរ។ ដោយសារការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង មិនយល់ព្រមបង្អង់ដំណើរការនីតិវិធីនេះ។ នេះជាពាក្យ

ដែលត្រូវកែតម្រូវ។ សូមអរគុណ។

[០៩:២០:១២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

អនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី ត្រឡប់មកកាន់កៅអីរបស់គាត់ ដែលរៀបចំទុកនៅក្រោយមេធាវីរបស់គាត់វិញចុះ។

*(លោក អៀង សារី ចាកចេញពីវង់ក្រចកសេះ)*

[០៩:២១:១៣]

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅជនជាប់ចោទ ខៀវ សំផន និងមេធាវីរបស់លោក ខៀវ សំផន ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ របស់សហព្រះរាជអាជ្ញា។

អនុរក្សមន្ទីរឃុំឃាំងនាំ ខៀវ សំផន ទៅកាន់ឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ!

*(លោក ខៀវ សំផន ចូលទៅកាន់វង់ក្រចកសេះ)*

**លោក ម៉ៃខល ផេសមិន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមមេធាវីលើកឲ្យខ្ចីបានហើយ ជៀសវាងការជ្រៀតជ្រែករំខានដល់ពេលវេលា ដែលអង្គជំនុំជម្រះបានចែកឲ្យមេធាវីក្រុមផ្សេងទៀត។

[០៩:២២:៥៣]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអភ័យទោសលោកប្រធាន! ពីម្សិលមិញនេះ ខ្ញុំដូចជាជឿច្បាស់ថា យើងមិនបានអនុញ្ញាតឲ្យការឆ្លើយតបទៅនឹងសេចក្តីចោទប្រកាន់របស់សហព្រះរាជអាជ្ញា ហើយខ្ញុំសូមជំទាស់ទៅលើសេចក្តីសម្រេចពេលនោះឥឡូវនេះ ហើយសូមឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញ។

ដូចដែលយើងខ្ញុំបានពន្យល់ពីម្សិលហ្នឹងគឺថា យើងបានយោងទៅរកថា កូនក្តីរបស់យើងបានឆ្លើយតបរួចទៅហើយ ហើយការឆ្លើយយោងទៅរកនោះគឺមិនត្រូវទេ។ ការបោះបង់សិទ្ធិនោះគឺថា មិនអាចបោះបង់បាន ហើយក៏មិនអាចយោងទៅរកគំនិតនេះបានដែរ ហើយលើកលែងតែបានធ្វើជាគ្មាន

លក្ខខណ្ឌ។

[០៩:២៣:៤៣]

យើងយល់ថា ពាក្យសុំចំពោះពីភាគីយើងនោះមិនត្រូវបានទទួលច្បាស់លាស់ទេ ហើយយើងនឹងបញ្ជាក់ច្បាស់ ប៉ុន្តែខ្ញុំគិតថា ខ្ញុំជឿថា នេះមិនមែនមានន័យថា កូនក្តីរបស់ខ្ញុំ ហើយសហសេវិករបស់ខ្ញុំគឺត្រូវបានដកហូតនូវសិទ្ធិមិនឲ្យឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញានោះទេ។តាមពិតលោក ខៀវ សំផន លោកអាចបន្ត ហើយយើងខ្ញុំសូមអនុញ្ញាតនឹងបន្តធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបរបស់យើងខ្ញុំទៅនឹងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់សហព្រះរាជអាជ្ញាបន្ទាប់ពីនេះបាទ។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់សាជាថ្មីម្តងទៀត ម្សិលមិញអង្គជំនុំជម្រះបានសម្រេចរួចហើយ គឺផ្តល់ពេលវេលាមួយកន្លះថ្ងៃសម្រាប់ក្រុមមេធាវីរបស់លោកជាមួយនឹងជនជាប់ចោទផងដែរ។ ប៉ុន្តែពេលវេលានោះត្រូវបានប្រើប្រាស់ដោយជនជាប់ចោទពីរម៉ោង។ ផ្ទុយទៅវិញគឺ មេធាវីមិនបានប្រើទេ ទោះបីអង្គជំនុំជម្រះរំឭកច្រើនលើកច្រើនសាក៏ដោយ។ ដូច្នេះ ពេលវេលាដែលបានបែងចែកឲ្យនោះ គឺបានកន្លងផុតទៅហើយ។ អ៊ីចឹងគឺអង្គជំនុំជម្រះមិនផ្តល់ឱកាសឲ្យក្រុមមេធាវីការពារក្តី នួន ជា ហ្នឹង ធ្វើសេចក្តីសន្និដ្ឋានតបទៀតទេ។ ពេលវេលាបានផុតទៅហើយ គឺវសៀលកាលពីម្សិលមិញ។ ពាក្យពេចន៍នេះទំនងជាច្បាស់លាស់ហើយ។

តទៅនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តីលោក ខៀវ សំផន និង លោក ខៀវ សំផន ដើម្បីធ្វើសេចក្តីសន្និដ្ឋានតប។ ហើយលោក ខៀវ សំផន អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកអង្គុយធ្វើសេចក្តីថ្លែងការណ៍នេះ។

សូមអញ្ជើញបាទ!

[០៩:២៥:៥១]

**លោក ខៀវ សំផន៖**

លោកប្រធាន លោក និងលោកស្រីចៅក្រមទាំងអស់ ព្រះសង្ឃជាទីសក្ការៈ បងប្អូនរួមជាតិជាទីគោរពស្នេហា។ អស់រយៈពេលពីរថ្ងៃហើយ ដែលយើងបានស្តាប់សេចក្តីសន្និដ្ឋានបើកសវនាការរបស់សហព្រះរាជអាជ្ញាក្នុងតុលាការនេះ។ ខ្ញុំមិនសូវយល់ដឹងអំពីនីតិវិធីនេះទេ ហើយតាមពិតទៅតាមការស្មានរបស់ខ្ញុំ ក៏គ្មានអ្នកណាម្នាក់ដែលដឹងច្បាស់នោះដែរ ព្រោះថាតុលាការនេះបានរៀបចំអ្វីៗសម្រាប់

តែសម្រួលដល់ខ្លួនតែប៉ុណ្ណោះ សម្រាប់រឿងក្តីនេះ។

[០៩:២៧:១៥]

និយាយថា អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែខ្ញុំសង្ឃឹមថាវាមិនមែនមានន័យថា នៅតុលាការនេះវាមិនចាំបាច់ផ្តល់ភស្តុតាងសម្រាប់គាំទ្រអ្វី ដែលគេបានអះអាងនោះឡើយ។ ក៏ប៉ុន្តែអស់រយៈពេលពីរថ្ងៃនេះខ្ញុំមានអារម្មណ៍ថា វាខុសពីសេចក្តីរំពឹងរបស់ខ្ញុំ។ នៅពេលចាប់ផ្តើមសវនាការនោះ ខ្ញុំយល់ឃើញថាសហព្រះរាជអាជ្ញាបានត្រឹមតែធ្វើការចោទប្រកាន់ដោយស្មានៗ។ ការអះអាងដោយគ្មានភស្តុតាង និងផ្គុំរឿងនេះបន្តិចរឿងនោះបន្តិចតែប៉ុណ្ណោះ។

នាថ្ងៃនេះ លោកប្រធានបានផ្តល់ឱកាសឲ្យរូបខ្ញុំនិយាយ។ តើឲ្យខ្ញុំឆ្លើយតបទៅលោកស្រី ជាលាង សហព្រះរាជអាជ្ញាជាតិយ៉ាងម៉េច? បើគាត់មិនបានលើកឈ្មោះសាក្សីណាម្នាក់មកបញ្ជាក់រឿងដែលគាត់លើកយកមកនិយាយទាល់តែសោះ ហើយជាញឹកញាប់ គាត់បានតែនិយាយពីសក្ខីកម្មអនាមិក។ ខ្ញុំមិនអាចធ្វើការឆ្លើយតបអ្វីបានឡើយ បើគាត់មិននិយាយពីភស្តុតាងឲ្យច្បាស់សោះនោះ។ ឲ្យខ្ញុំឆ្លើយតបទៅលោកស្រីព្រះរាជអាជ្ញាជាតិយ៉ាងម៉េច បើការបង្ហាញរបស់គាត់ភាគច្រើនសំអាងតែទៅលើអត្ថបទដកស្រង់ចេញពីសៀវភៅ និងអត្ថបទរបស់អ្នកកាសែតនោះ? តាមខ្ញុំដឹងអ្នកប្រវត្តិសាស្ត្រក្តី អ្នកកាសែតក្តី អ្នកចងក្រងរឿងខ្លីៗសម្រាប់អ្នកកាសែតក្តី ឬក៏អ្នកប្រលោមលោកក្តី មិនមែនជាចៅក្រមទេ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកគេ បានស្បថធ្វើជាចៅក្រមស៊ើបអង្កេត សម្រាប់ដាក់បន្ទុក ឬដោះបន្ទុកកុំឲ្យលម្អៀងនៅក្នុងមតិរបស់ពួកគេសោះទេ។ អ្នកកាសែតដែលលោកស្រីបានលើកឡើងទាំងនេះ អត់ជាប់ចំណងពាក្យសន្យាតាមផ្លូវច្បាប់ទេ។ ពួកគេមានសិទ្ធិភ័ន្តច្រឡំតាមចិត្ត លម្អៀងតាមចិត្ត និងបញ្ចេញមតិពួកគេតាមចិត្ត ដោយមិនបាច់ពិចារណាលើចំណុចណាមួយឲ្យបានជ្រៅជ្រះនោះទេ។ តើខ្ញុំអាចជម្រាបលោកស្រីសហព្រះរាជអាជ្ញាជាតិថា ក្រោយពីថ្ងៃ១៧ មេសា ១៩៧៥ កាសែតបារាំងឈ្មោះ ឡឺម៉ុងដ៍ បានចុះផ្សាយអត្ថបទមួយដែលមានចំណងជើង "ក្រុងភ្នំពេញត្រូវបានរំដោះហើយ" ខ្ញុំជឿជាក់ថា លោកស្រីច្បាស់ជាទិតៀនខ្ញុំមិនតិចទេ បើសិនបើខ្ញុំឆ្លៀតឱកាសយកអត្ថបទកាសែតនោះមកប្រើ។

[០៩:៣២:៣៨]

ដោយមូលហេតុនេះហើយ ដែលនាំឲ្យខ្ញុំយល់យ៉ាងច្បាស់ថា ដោយលោកស្រីបានអានកាសែតនោះច្រើនពេកទៅ នាំឲ្យលោកស្រីក៏ជឿទាំងស្រុងថាខ្ញុំបានប្រព្រឹត្តឧក្រិដ្ឋកម្មនេះ ឧក្រិដ្ឋកម្មនោះ ដែល

ធ្វើឲ្យខ្ញុំមានការបារម្ភ ព្រោះថាវាជារឿងក្ដីរបស់ខ្ញុំ មិនមែនជាសន្និសីទ ឬការប្រជុំនយោបាយណាមួយឡើយ។ ទាក់ទងនឹងចំណុចនេះ សហការីរបស់លោកស្រី លោកសហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយសើចចំអកថា ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ខ្មែរមិនមានសិទ្ធិទទួលបាននូវការកាត់ក្ដីដែលមានគុណភាពដូចការកាត់ក្ដីដែលកំពុងបើកនាថ្ងៃនេះទេ។ តើវាជាការកាត់ក្ដីប្រភេទណាទៅ ដែលផ្ដល់ឲ្យយើងខ្ញុំនេះ ៣៦ឆ្នាំ ក្រោយពីហេតុការណ៍ដែលបានកន្លងផុតទៅហើយ បើសំអាងទៅលើសាក្សីអនាមិក អត្ថបទសារព័ត៌មានផ្សេងៗ និងសៀវភៅរបស់កាសែតដែលលម្អៀងនោះ?

លោកសហព្រះរាជអាជ្ញាបានរំឭកថា ពេលខ្ញុំនៅជានិស្សិត ខ្ញុំបានចូលរួមក្នុងការប្រជុំរបស់និស្សិតកុម្មុយនីស្ដជាច្រើននៅប៉ារីស។ លោកហាក់ដូចជាចង់អះអាងថា មហាឧក្រិដ្ឋកម្មរួមជាមួយនឹងអ្នកជាប់ចោទជាមួយខ្ញុំនេះ វាចាប់ផ្ដើមតាំងពីនោះមកហើយ តែខ្ញុំសូមរំឭកលោកសហព្រះរាជអាជ្ញាថា កាលនៅប៉ារីស ខ្ញុំក៏បានរៀនសូត្រ ហើយបានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចរបស់ខ្ញុំយ៉ាងជោគជ័យផងដែរ។ ជាការពិតណាស់ ខ្ញុំក៏បានចាប់អារម្មណ៍ពីលទ្ធិកុម្មុយនីស្ដ ហើយខ្ញុំក៏បានសិក្សាអំពីអ្នកទ្រឹស្ដីលទ្ធិកុម្មុយនីស្ដដែរ។ ចុះយ៉ាងម៉េច? នៅថ្ងៃនេះ លោកអស់សំណើច ពេបជ្រាយ ប៉ុន្តែខ្ញុំត្រូវរំឭកលោកថា នាពេលនោះកុម្មុយនីស្ដ គឺជាចលនាមួយដែលផ្ដល់សេចក្ដីសង្ឃឹមដល់យុវជនរាប់លាននាក់ នៅលើសកលលោកទាំងមូល។

[០៩:៣៧:២២]

អ្វីដែលខ្ញុំចង់បាននាពេលនោះ គឺអ្វីដែលជាពិសោធន៍ល្អសម្រាប់ប្រទេសខ្ញុំ ប្រទេសកម្ពុជា។ លោកសហព្រះរាជអាជ្ញាមិនមែនដោយលោកចោទប្រកាន់លើរូបខ្ញុំថា ជាតំណាងកម្លាំងចង្រៃនោះ លោកនឹងអាចនាំឲ្យគេជឿថា យុវភាពរបស់ខ្ញុំគឺជាយុវភាពរបស់ឃាតកម្នាក់នោះទេ។ ប៉ុន្តែលោកនៅតែព្យាយាមបន្លែបន្លំ បំភ័យ ដោយលើករឿងថា បន្ទាប់ពីបានបញ្ចប់ការសិក្សានៅស្រុកបារាំង ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ ខ្ញុំបានលាក់បាំងខ្សែទាក់ទងចង្រៃរបស់ខ្ញុំ ហើយធ្វើឫកជាទន់ភ្លន់ សុភាពរាបសាររបស់ខ្ញុំ។ តាមលោកស្មានដោយសារតែអំពើពុតត្បុតរបស់ខ្ញុំនេះហើយ ដែលនាំឲ្យខ្ញុំបានជាប់ឆ្នោតជាតំណាងរាស្ត្រពីរលើក ហើយត្រូវបានសម្ដេច សីហនុ ជ្រើសតាំងខ្ញុំជារដ្ឋលេខាធិការ។ ពេលស្ដាប់លោកនិយាយ ខ្ញុំចោទសួរខ្លួនឯងថា តើលោកពិតជាជឿអ្វីដែលលោកបាននិយាយមែនឬទេ? ឬក៏លោកត្រូវមោហ៍បាំង បានជាលោកងងឹតងងុលដោយគោលបំណងរបស់លោកជាខ្លាំងពេក ថាធ្វើម៉េចផ្ដន្ទាទោសលើរូបខ្ញុំឲ្យខាងតែបាន។ លោកហាក់ដូចជាចង់ធ្វើឲ្យគេស្ដាប់ការរៀបរាប់ផ្ដេសផ្ដាសរបស់

លោកពេកទៅ រហូតដល់លោកអះអាងថា ភស្តុតាងដែលបង្ហាញឲ្យឃើញថា ខ្ញុំជាបិសាចនោះនៅត្រង់ដែលអ្នករាជការគ្រាន់តែសង្ស័យថាខ្ញុំជាមនុស្សខាងឆ្វេង ខ្ញុំក៏ភ័យខ្លួន ស្ទន់ស្ទោ រត់ចូលព្រៃដោយខ្លួនឯងទៅ។ ប៉ុន្តែលោកសហព្រះរាជអាជ្ញាលោកភ្លេចថា ឆ្វេងនិយមរបស់ខ្ញុំដែលលោកបាននិយាយនោះគឺជាការប្រឆាំងទៅនឹង លន់ នល់ និងបក្ខពួករបស់គាត់ដែលសម្តេច សីហនុ ហៅមកវិញដោយភ័ន្តច្រឡំ។

កាលពីឆ្នាំ១៩៦៩ ចំពេលដែលគេកំពុងនាំគ្នារៀបចំធ្វើរដ្ឋប្រហារផ្តួលរំលំសម្តេច លោកហាក់ដូចជាគិតថា ខ្ញុំនិយាយយ៉ាងនេះមិនត្រូវទេ បើដូច្នេះ ហេតុអ្វីក៏លោកមិនកោះយាងសម្តេចឲ្យលោកយាងមកអង្គុយកៅអីចុងចោទជាមួយយើងខ្ញុំផងទៅ? លោកសហព្រះរាជអាជ្ញា លោកភ្លេចហើយថា ចន្លោះខែមករា ឆ្នាំ១៩៧០ និង ខែសីហា ១៩៧៣ ពោលគឺអស់រយៈពេលពីរឆ្នាំកន្លះ អាមេរិកបានទម្លាក់គ្រាប់បែកមកលើកម្ពុជាដ៏តូចនេះច្រើនជាងគ្រាប់បែក ដែលកម្លាំងសម្ព័ន្ធមិត្តបានទម្លាក់ក្នុងសង្គ្រាមលោកលើកទីពីរនៅគ្រប់សមរភូមិទៅទៀត រួមបញ្ចូលទាំងគ្រាប់បែកទាំងពីរគ្រាប់ដែលបានទម្លាក់ទៅលើក្រុងហ៊ីរ៉ូស៊ីម៉ា និង ណាហ្គាសាគី ផងដែរ។

[០៩:៤៣:៥៣]

សូមលោកអញ្ជើញគិតមើលៗ តើប្រទេសខ្ញុំទៅជាយ៉ាងណាក្រោយពីការសម្លាប់រង្គាលយ៉ាងនេះ? សូមអស់លោកជួយគិតមើលចុះ តើប្រជាជនកម្ពុជា និងប្រទេសកម្ពុជាស្ថិតក្នុងសភាពបែបណានៅពេលមានការទម្លាក់គ្រាប់បែកយ៉ាងនេះ? អត់ទេ ឃើញថាលោកមិនព្រមគិតរឿងនេះទេ ចំពោះលោកៗចូលចិត្តនិយាយពីឆ្នាំ១៩៧៥, ១៩៧៩ ជាង ដោយបំភ្លេច ឬដោយកែក្រឡៃប្រវត្តិសាស្ត្រនៅរយៈកាលនោះទៅវិញ។ ទោះជាលោកពេញចិត្ត ឬមិនពេញចិត្តក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនបានគាំទ្រចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់។ ទោះជាលោកពេញចិត្ត ឬមិនពេញចិត្តក៏ដោយ គឺជាចលនាប្រឆាំងនឹងការជិះជាន់នៅពេលដែលរដ្ឋប្រហាររបស់លោក លន់ នល់ នៅឆ្នាំ១៩៧០ ហើយនៅខណៈដែលភ្លើងសង្គ្រាមវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា គឺរូបខ្ញុំជាអ្នកទទួលបន្ទុក ទាក់ទងរវាងសម្តេច សីហនុ និងអ្នកតស៊ូនៅក្នុងប្រទេស ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ តើនេះជាឧក្រិដ្ឋកម្មឬ? គេបានចោទប្រកាន់ខ្ញុំថាខ្ញុំបានជួយ ប៉ុល ពត ឲ្យមកកាន់អំណាច ប៉ុន្តែខ្លួនខ្ញុំវិញ ខ្ញុំដឹងច្បាស់ថាខ្ញុំបានរួមចំណែកឲ្យមានការរួបរួមកម្លាំងជាតិ ដើម្បីការពារមាតុភូមិរបស់ខ្ញុំ ដែលប្រាថ្នាចង់រស់នៅជាប្រជាជាតិមួយដែលអធិបតេយ្យ ឯករាជ្យ ទាំងចំពោះសហរដ្ឋអាមេរិក ទាំងចំពោះវៀត-

ណាមកុម្មុយនីស្ត ដែលតែងតែរិះរកគ្រប់មធ្យោបាយ ដើម្បីបញ្ចូលប្រទេសខ្ញុំឲ្យចូលទៅក្នុងសហព័ន្ធឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់វៀតណាម។

ក្នុងស្ថានការណ៍បែបនេះ ម្ដេចក៏លោកប៊ិានអះអាងថា ខ្ញុំមានគំនិតចង់បំផ្លាញប្រជាជនកម្ពុជា ដែលខ្ញុំស្រឡាញ់ជាងអ្វីៗទាំងអស់ ហើយដែលខ្ញុំខិតខំការពារមួយជីវិតខ្ញុំមកហើយនេះ។ អ្វីដែលអស់លោកលើកឡើងកាលពីថ្ងៃចន្ទ និងថ្ងៃអង្គារ គឺជាការលម្អៀងខ្លាំងសម្បើមណាស់។ នៅពេលស្ដាប់លោកនិយាយពីរឿងដែលគ្មានអ្វីច្បាស់លាស់បន្តិចសោះ ហើយរៀបចំតុបតែងរឿង ហើយគេយល់ថាជាការពិតនោះ។ ខ្ញុំមានអារម្មណ៍ថា លោកចង់បានក្បាលខ្ញុំឲ្យទាល់តែបាន ទោះជាបីជាត្រូវឆ្លងតាមការរៀបចំកាត់ទោសដោយច្បោលៗ បន្លែបន្លំយ៉ាងណាក៏ដោយ ទោះបីជាការជេរប្រមាថដល់ជនរងគ្រោះដែលលោកអះអាងថា ការពារក៏ដោយ។

[០៩:៤៩:៤៦]

មែនទែនទៅ អ្វីតែមួយគត់ដែលខ្ញុំបានធូរចិត្តធូរថ្លើម ក្រោយពីបានស្ដាប់លោកអស់រយៈពេលយ៉ាងយូរទៅ គឺលោកទទួលស្គាល់ថា មុនរំដោះភ្នំពេញ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទីក្រុងនេះស្ថិតក្នុងសភាពដែលអាចក្លាយទៅជាមហន្តរាយដ៏ធំធេងដល់អាយុជីវិតមនុស្សទៅហើយ។ លោកទទួលស្គាល់ថា ពុំមានអ្វីហូបទេ ហើយក៏គ្មានថ្នាំសង្កូវដែរ។ ដូចខ្ញុំបានជម្រាបរួចហើយ ប្រជាជនភាគច្រើនបានរត់គេចពីការទម្លាក់គ្រាប់បែកដ៏សែនអប្រិយរបស់អាមេរិក មកជ្រកកោននៅទីក្រុង សង្ឃឹមថានឹងទទួលបានការការពារ។ នៅពេលលោកមានប្រសាសន៍នោះ បើទោះជាខ្ញុំមិនមានការទទួលខុសត្រូវសូម្បីតែតិចតួចក្នុងការសម្រេចជម្លៀសប្រជាជនពីទីក្រុងក៏ដោយ ខ្ញុំនៅតែមានសេចក្ដីសង្ឃឹមតូចមួយដោយគិតក្នុងចិត្តខ្ញុំ ថាលោកពិតជាមិនប៊ិានបន្តចោទប្រកាន់យើងខ្ញុំទៀតទេ បើមើលទៅតាមការដែលលោកទើបតែទទួលស្គាល់ស្ថានភាពអាក្រក់នោះ មានទទួលស្គាល់ថា ស្ថានភាពអាក្រក់នោះមានរួចជាស្រេចទៅហើយ មុនពេលយើងខ្ញុំមកដល់ទីក្រុងភ្នំពេញ។

[០៩:៥២:១៨]

ប៉ុន្តែ សេចក្ដីសង្ឃឹមរបស់ខ្ញុំបានតែមួយភ្លែតប៉ុណ្ណោះ លោកក៏ចាប់ផ្ដើមនិយាយពីសំណុំរឿងរាប់រយពាន់ទំព័រ ហាក់បីដូចជាចំនួនទំព័រទាំងអស់នោះ វាជាភស្តុតាងដូច្នោះដែរ។ ម្យ៉ាងទៀត គួរតែទាំងអស់គ្នាមានលទ្ធភាពអានឯកសាររាប់រយពាន់ទំព័រនោះ។ តែឯកសារចំនួនរាប់សិបពាន់ទំព័រមិនទាន់បានបកប្រែ ទោះជាភាសាអង់គ្លេសក្ដី ជាភាសាបារាំងក្ដី គឺគ្មានបកប្រែជាភាសាទាំងពីរនេះទេ។

ម្យ៉ាងទៀត តើលោកផ្ទាល់ខ្លួនលោកបានអានឯកសារទាំងនោះអស់ហើយឬនៅ? ខ្ញុំពិបាកជឿថា លោកបានអានណាស់។ បើសិនជាលោកបានអានអស់មែន តើលោកនៅតែប៊ានអះអាងថា ខ្ញុំជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្នុងឋានៈ ដែលគ្មានឯកសារណាមួយទាល់តែសោះបញ្ជាក់ថាខ្ញុំជាសមាជិកគណៈអចិន្ត្រៃយ៍ ហើយនៅក្នុងខណៈដែលអស់លោកមានតែកំណត់ហេតុតែ១៩ សម្រាប់អង្គប្រជុំ ដែលមានចំនួនសរុបពី១៥០ ទៅ២០០លើក ដែលបានប្រព្រឹត្តទៅពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បើប្រសិនជាលោកបានអានសំណុំរឿង តើលោកនៅតែប៊ានអះអាងថា នៅក្នុងចំណោមឯកសារទាំងនោះ ច្បាស់ជាមានភស្តុតាងគាំទ្រ ការចោទប្រកាន់របស់លោកឬទេ? ក្នុងខណៈដែលនៅក្នុងចំណោមអង្គប្រជុំទាំង១៩លើក ដែលអស់លោកមានភស្តុតាងជាឯកសារថា ខ្ញុំបានចូលរួមក្នុងប្រជុំ១៤លើកមែន។ តែខ្ញុំបាននិយាយតែពីរដង គឺនិយាយតែពីប្រធានបទដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្ញុំមិនជាប់ទាក់ទងអ្វីទាល់តែសោះ ទៅនឹងរឿងឧក្រិដ្ឋកម្មដែលអស់លោកចោទប្រកាន់លើរូបខ្ញុំនេះ។

លោកសហព្រះរាជអាជ្ញា! ហេតុអ្វីក៏គ្មានឯកសារណាមួយដែលបញ្ជាក់ថាខ្ញុំជាសមាជិកគណៈអចិន្ត្រៃយ៍ជាផ្លូវការ? ហេតុអ្វីក៏គ្មានឯកសារណាមួយដែលបញ្ជាក់ថាខ្ញុំបានធ្វើជាប្រធានមន្ទីរនយោបាយ ៨៧០ វាគ្មានអ្វីក្រៅពីខ្ញុំមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ ក្រៅពីខ្ញុំមិនមែនជាប្រធានគណៈនយោ-បាយ៨៧០នោះទេ ប្រធានមន្ទីរនយោបាយ៨៧០នោះទេ។

[០៩:៥៧:០៨]

នេះជាការពិត ទោះជាវាមិនស្របនឹងការស្មានរបស់លោកក៏ដោយ។ នៅពេលដែលអានដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ខ្ញុំបានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានប្រឌិតពាក្យថា កន្លែងមជ្ឈិមនៃបក្ស *សង់ត្រើស ឌុយ ប៉ាទី* ។ ខ្ញុំស្តាប់ឮកាលពីថ្ងៃចន្ទ និងថ្ងៃអង្គារ ដោយចិត្តបារម្ភគិតថា លោកប្រើពាក្យនេះដើម្បីធ្វើយ៉ាងណាគេចមិនព្រមបែងចែកឲ្យច្បាស់រវាងគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ ព្រោះវារំខានលោក។ តែកាលពីសម័យកាលនោះ វាមានច្បាស់យ៉ាងនេះ។

ដូច្នេះ លោកចង់ធ្វើឲ្យសាធារណជនជឿថា មនុស្សទាំងអស់គ្នាសុទ្ធតែជាត្រីដែលនៅកន្ត្រកតែមួយ។ តែនេះជារឿងភូតកុហក ជាការបំភ្លៃការពិត។ លោកដឹងច្បាស់ហើយថា កម្ពុជាប្រជាធិបតេយ្យមានរចនាសម្ព័ន្ធមួយដែលបែងចែកជាផ្នែកតូចៗ ដាច់ដោយឡែកពីគ្នា ហើយមានលាក់ការណ៍សម្ងាត់ខ្ពស់ណាស់។

លោកព្រះរាជអាជ្ញា! លោកបានលើកឡើងថា ការណ៍ដែលខ្ញុំត្រូវបានតែងតាំងជាប្រធានគណៈ

ប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ នាំឲ្យខ្ញុំស្ថិតនៅក្នុងសហឧក្រិដ្ឋកម្មរួម។ បើអ៊ីចឹង ហេតុដូចម្ដេចក៏លោកមិនធ្វើការចោទប្រកាន់លើព្រះមហាវីរក្សត្រនរោត្តម សីហនុ ដែរទៅ? លោកដឹងច្បាស់ថា គណៈប្រធានរដ្ឋគ្រាន់តែជារបស់មួយដែលគេតាំងឲ្យល្អមើលតែប៉ុណ្ណោះ គ្មានអ្វីពិតប្រាកដទេ រហូតទាល់តែមិនដែលមានកិច្ចប្រជុំលើកណាសោះ។ បើអ៊ីចឹងគេអាចប្រព្រឹត្តឧក្រិដ្ឋកម្មអ្វីបានទៅ បើគ្មានរូបគ្មានរាងយ៉ាងនេះ?

[១០:០១:១២]

លោកលើកឡើងថា ខ្ញុំប្រាកដជាដឹង ពីស្ថានភាពប្រជាជនកម្ពុជានៅក្នុងរយៈកាលនោះ ពីព្រោះខ្ញុំបានធ្វើទស្សនកិច្ចការដ្ឋានលើកទំនប់ដីកប្រឡាយ។ តើលោកព្រះរាជអាជ្ញាផ្ទាល់ខ្លួនលោក ច្បាស់ជាជឿអ៊ីចឹងមែនឬ? នៅពេលដែលខ្ញុំដង្ហែដំណើរព្រះករុណាទៅមើលការដ្ឋាននោះ។ ស្រាប់តែគេសម្លាប់ប្រជាជននឹងត្បូងចប ឬបាញ់សម្លាប់នៅចំពោះមុខយើងទាំងអស់គ្នាយ៉ាងនេះ? ចំពោះខ្ញុំ ពាក្យពេចន៍របស់លោកទាំងពីរនាក់ ហាក់ដូចជាកាន់តែពិបាកជឿនៅពេលដែលអ្នកស្រីសហព្រះរាជអាជ្ញាអះអាងថា កាលពីម្សិលម៉្ងៃថា អង្គការបានចេញសេចក្តីណែនាំឲ្យមានការរៀបចំ ដោយឲ្យមានរៀបចំការដោយបង្ខំ និងធ្វើយ៉ាងណាតាមដានមនុស្សម្នាក់ៗថាបានរួមដំណេកជាមួយគ្នាដែរឬអត់?

ពិតណាស់ ខ្ញុំមិនមែនជាសមាជិកអង្គការទេ តែខ្ញុំស្មានដឹងថា ក្នុងការគ្រប់គ្រងប្រទេសមួយទាំងមូល សមាជិករបស់អង្គការមានកិច្ចការផ្សេងទៀតច្រើនណាស់ដែលត្រូវធ្វើ មិនមានពេលឯណាមកតាមដានមើលការផ្សំដំណេករបស់ប្រជាជនឡើយ។ រឿងដែលលោកស្រីមានប្រសាសន៍មិនគួរយកមកនិយាយទេ។ ខ្ញុំដូចជាអៀនខ្មាសក្នុងការលើកយករឿងនេះមកនិយាយ ប៉ុន្តែខ្ញុំប៊ាននិយាយនេះដើម្បីតែឆ្លើយតបទៅអស់លោកសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

[១០:០៤:១១]

លោកសហចៅក្រមស៊ើបអង្កេតនិងកាសែតមួយចំនួនបានបន្ទោសខ្ញុំថា ខ្ញុំនិយាយប្រែប្រួលផ្លាស់ប្តូរក្នុងសេចក្តីប្រកាសនិងនៅក្នុងសៀវភៅរបស់ខ្ញុំ។ ជាការពិត ខ្ញុំមានការវិវត្តន៍មែន ឯការវិវត្តន៍នេះវាកើតឡើងបន្តិចម្តងៗនៅពេលដែលខ្ញុំបានដឹងរឿង និងបានគិតពិចារណាពីសម័យកាលនោះនៃប្រវត្តិ-សាស្ត្រយើង។ តើគេអាចយកដំណើរការនៃការគិតពិចារណារបស់ខ្ញុំនេះ មកប្រឆាំងនឹងរូបខ្ញុំដែរឬទេ? ខ្ញុំមិនអាចជឿបានទាលតែសោះ។ លោកមេធាវីរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំគួរតែកម្រិតការនិយាយតែត្រឹមព្រឹត្តិការណ៍ដែលខ្ញុំបានឃើញ ដែលខ្ញុំបានដឹងកាលពីសម័យនោះ។ ប៉ុន្តែអស់លោក លោកស្រីចៅក្រម ខ្ញុំ

មានសំណូមពរអស់លោក លោកស្រី សូមអធ្យាស្រ័យខ្ញុំផង មិនមែនជារឿងដែលអាចធ្វើបានងាយៗទេ ព្រោះថារយៈពេល៣៦ឆ្នាំ បានកន្លងផុតទៅហើយ តាំងពីឆ្នាំ១៩៧៥ មកហើយ។ មនុស្សម្នាក់ៗក្នុងរយៈពេល៣៦ឆ្នាំ ប្រាកដជាត្រូវការចង់យល់ ចង់ដឹង ហើយចេះតែវិវត្តន៍ហើយ នៅពេលដែលដឹងបណ្ដើរៗ ដែលបានដឹងយល់បណ្ដើរៗ។

[១០:០៦:៤៣]

ទោះជាអ្វីដែលខ្ញុំទើបតែនិយាយយ៉ាងនេះក៏ដោយ យ៉ាងណាក៏ដោយ ខ្ញុំនៅតែសង្ឃឹមថា យ៉ាងហោចណាស់តុលាការនេះ ក៏អាចជាឱកាសឲ្យខ្ញុំបានពន្យល់ដល់ជាតិយើង ដើម្បីយល់ថា ហេតុម្ដេចបានជាខ្ញុំដែលជាអ្នកកាន់តំណែងមួយខ្ពស់ជាផ្លូវការ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យហើយ ខ្ញុំនៅតែថាមិនដែលបានចូលរួមសម្រេចកិច្ចការអ្វីធំដុំសោះ ហើយមិនបានដឹងទាល់តែសោះ អំពីអ្វីដែលបានកើតមាននៅក្នុងប្រទេសយើងពីពេលនោះ។ ដោយព្រមទាំងរឿងគួរឲ្យរន្ធត់ ដូចដែលអ្នកស្រីសហព្រះរាជអាជ្ញាបានលើកឡើងកាលពីថ្ងៃចន្ទ ទី២១ ខែវិច្ឆិកា។

ខ្ញុំបានសន្យាជាមួយបងប្អូនរួមជាតិហើយ ថាខ្ញុំនឹងព្យាយាមគោរព ហើយខ្ញុំនឹងព្យាយាមគោរពតាមពាក្យសន្យានោះ។ នេះជាការងារមួយលំបាករបស់ខ្ញុំ តែខ្ញុំមានជំនឿជឿជាក់ថា ដំណើរការរបស់តុលាការកាន់តែឈានទៅមុខជាបណ្ដើរៗ ទៅព្រះសង្ឃ និងបងប្អូនរួមជាតិនឹងទតឃើញដោយព្រះអង្គផ្ទាល់។ បងប្អូនរួមជាតិនឹងអាចនវិនិច្ឆ័យបានដោយខ្លួនឯងផ្ទាល់។

សូមអរព្រះគុណ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ខៀវ សំផន។ ហើយអនុរក្សមន្ទីរឃុំឃាំង នាំគាត់ទៅកាន់កៅអីរបស់គាត់ដែលបានរៀបចំទុកនៅក្រោយមេធាវីរបស់គាត់វិញចុះ!

*(លោក ខៀវ សំផន ចាកចេញពីវង់ក្រចកសេះ)*

ឥឡូវនេះដើម្បីឲ្យកិច្ចដំណើរការ នៃការថ្លែងនូវសេចក្ដីសន្និដ្ឋានតបរបស់មេធាវី ខៀវ សំផន ប្រព្រឹត្តទៅបានល្អហើយនោះដោយសារពេលវេលានេះវាសមល្មមនឹងសម្រាកផង។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការនីតិវិធីស្ដាប់នូវសេចក្ដីសន្និដ្ឋានតបរបស់មេធាវីការពារក្ដីរបស់លោក ខៀវ សំផន ទៅនឹងសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។

[១០:១០:៤២]

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលបានធ្វើដោយសង្ខេបរួចហើយនេះ ហើយអង្គជំនុំជម្រះសូមជម្រាបថា សហមេធាវីទាំងពីររូប ដែលមានពេលវេលាកន្លះថ្ងៃ ប៉ុន្តែដោយព្រឹកមិញដោយមានការរអាក់រអួលនូវបញ្ហាខ្លះ អ៊ីចឹងគឺអតិបរមាគឺត្រឹមម៉ោងដប់ពីរ និងម្ភៃនាទី។ សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

ជាបឋម ខ្ញុំបាទសូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គដែលមានវត្តមាននៅទីនេះ។ ហើយសូមជ្រាបសួរបងប្អូនជនរួមជាតិ ជាទីមេត្រី និងសូមគោរពអង្គសវនាការទាំងមូល។

[១០:៣៥:០៣]

មុននឹងចាប់ផ្តើមនេះ ខ្ញុំបាទសូមធ្វើការកត់សម្គាល់តូចមួយថា ខ្ញុំត្រូវបានតុលាការ អ.វ.ត.ក នេះទទួលស្គាល់ជាផ្លូវការពីថ្ងៃសុក្រ សប្តាហ៍មុននេះ ហើយត្រូវឡើងមកធ្វើសេចក្តីសន្និដ្ឋាននៅពេលនេះ។ ដូច្នេះ ពេលវេលានេះ ខ្ញុំជឿថាពិតជាចំណោទខ្លះក្នុងការធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ ប៉ុន្តែយ៉ាងណាក៏ដោយ អ្វីដែលក្រុមការពារបានធ្វើកន្លងរួចមកហើយអាចជាប្រយោជន៍ដែលអាចឲ្យខ្ញុំចូលរួមនៅក្នុងនីតិវិធីនេះបានដែរ។

ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដូចតទៅ៖ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ចំពោះកូនក្តីរបស់ខ្ញុំបាទលោក

ខៀវ សំផន។ ខ្ញុំបាទយល់ឃើញថា វាជាការចោទប្រកាន់មួយដ៏លំបាករបស់សហព្រះរាជអាជ្ញា ពីព្រោះថាវាជាការចោទប្រកាន់ទៅលើពេលវេលា-- ទៅលើបទល្មើសដែលកើតឡើងក្នុងពេលវេលាដ៏យូរ គឺជាពេលវេលាឆ្លងសតវត្សរ៍។ និយាយឲ្យខ្លីអំពើដែលត្រូវបានយកមកវែកញែកនៅក្នុងសវនាការនេះ នឹងត្រូវបង្ហាញជាបន្តបន្ទាប់ ដោយសាក្សី ឬក៏ត្រូវដេញដោលពីភស្តុតាង វាកើតឡើងជាង៣០ឆ្នាំហើយ។ ហើយការចងចាំរបស់សាក្សី ឬក៏ការបន្សល់ទុកភស្តុតាងនានា វាធ្វើឲ្យបាត់បង់នូវភាពជឿជាក់បានជាច្រើន។ ដូច្នេះ ការបង្ហាញភស្តុតាងក្តី ទាំងភស្តុតាងដាក់បន្ទុក ទាំងភស្តុតាងដោះដែលមាន-- យើងឃើញថានឹងមានកម្រិត។ ជាក់ស្តែង ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាគឺផ្អែកតែទៅលើសំណេររបស់អ្នកនិពន្ធ ជាអ្នកកាសែត ឬក៏អាចជាអ្នកស្រាវជ្រាវ ជាដើម។ ហើយដែលសំណេរទាំងអស់នោះ ក៏គ្មានការផ្ទៀងផ្ទាត់ថាត្រឹមត្រូវពិតប្រាកដនោះដែរ ពីព្រោះសំណេរខ្លះគឺបានធ្វើក្នុងរយៈពេលច្រើនឆ្នាំ បន្ទាប់ពីព្រឹត្តិការណ៍បានលើកឡើង។

[១០:៣៨:១៥]

ជាតទៅនេះ ខ្ញុំសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យទៅលើចំណុចបី ដែលទាក់ទងទៅនឹងអំពើទាំងឡាយដែលសហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់។ ទីមួយ គឺសូមពិនិត្យទៅលើ ថាតើអំពើដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ អ.វ.ត.ក នេះ ជាអំពើល្មើសដែរឬទេ? ក្នុងនាមជាមេធាវីការពារ ខ្ញុំមិនបដិសេធទេថា មានអំពើឃោរឃៅមួយចំនួនដែលកើតមានឡើងនៅក្នុងសម័យនោះ។ ក៏ប៉ុន្តែសួរថា តើអំពើនោះ វាជាអំពើល្មើសដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការ អ.វ.ត.ក នេះដែរឬទេ? សហព្រះរាជអាជ្ញាបានលើកបង្ហាញហើយថា យោងតាមច្បាប់ស្តីពីការបង្កើតតុលាការនេះ តុលាការ អ.វ.ត.ក មានសមត្ថកិច្ចពិនិត្យទៅលើមាត្រា៤ មាត្រា៥ និងមាត្រា៦ នៃច្បាប់នេះ ដែលជាមូលដ្ឋាននៃការចោទប្រកាន់។

[១០:៤០:០៦]

ទីបី ទោះបីថា មានអំពើដែលកើតឡើងក្នុងយុត្តាធិការរបស់តុលាការ អ.វ.ត.ក នេះកើតឡើងមានក៏ដោយ ជាបទល្មើសមែនក៏ដោយ សួរថា តើលោក ខៀវ សំផន ដែលជាកូនក្តីរបស់ខ្ញុំបាទនេះមានការទទួលខុសត្រូវចំពោះអំពើទាំងឡាយដែលកើតមានឡើងនោះដែរឬទេ? ដូច្នេះ ការបង្ហាញភស្តុតាងនានាត្រូវបញ្ជាក់ឲ្យបានច្បាស់ ឲ្យលើសពីវិមតិសង្ស័យដែលជាភារកិច្ច និងការទទួលខុសត្រូវរបស់

សហព្រះរាជអាជ្ញា។ អ្វីដែលខ្ញុំបាទអាចមើលឃើញពីព្រឹត្តិការណ៍ជារួម ជាខ្លឹមសាររួមនៅក្នុងសំណុំរឿងនេះ ខ្ញុំមើលឃើញថាវាហាក់ដូចជាសវនាការរវាងមនោគមន៍វិជ្ជាកុម្មុយនីស្ត និងមនោគមន៍វិជ្ជាសេរី ហេតុអី? នៅពេលដែលព្រឹត្តិការណ៍កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កាលនោះដូចលោក ខៀវ សំផន បានបញ្ជាក់អ៊ីចឹងក្នុងកាលដែលលោកនៅជាយុវវ័យ គឺចលនាកុម្មុយនីស្តវាបានកើតឡើងច្រើនរីករាលដាលពាសពេញពិភពលោក។

[១០:៤១:៤៨]

ប៉ុន្តែជាងកន្លះសតវត្សរ៍កន្លងមកនេះ មនោគមន៍វិជ្ជាកុម្មុយនីស្តបានរលត់សាបរលាបទៅវិញ វាលេចចេញនូវមនោគមន៍វិជ្ជាសេរី ឬក៏លទ្ធិប្រជាធិបតេយ្យសេរីជំនួសវិញ។ ការខុសគ្នានៃពេលវេលានេះ ហើយមិនមែនខុសតិចទេ គឺខុសរហូតដល់ឆ្លងសតវត្សរ៍ វាធ្វើឲ្យការអនុវត្តច្បាប់មិនមានភាពរលូនឡើយ។ ក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ អំពើហិង្សានយោបាយវាចាត់ទុកទៅជារឿងសាមញ្ញរបស់អ្នកនយោបាយ។ នៅស្រុកខ្មែរយើងក៏មានពាក្យនិយាយថា ធ្វើនយោបាយបើឈ្នះធ្វើស្តេច បើចាញ់ដេកព្រៃ ឬក៏ចូលគុក ឬក៏អាចស្លាប់។ អ៊ីចឹងអំពើហិង្សានយោបាយវាកើតឡើងនៅក្នុងបរិបទសង្គមមនុស្សមិនមែនតែសង្គមខ្មែរទេ នៅក្នុងកាលសម័យនោះមានច្រើនកន្លែង ដោយសារតែការប្រកាន់និន្នាការនយោបាយការពុំមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសនយោបាយរបស់បណ្តាប្រជាជាតិជារួម។ អ៊ីចឹងនៅពេលដែលសម័យបច្ចុប្បន្ន យើងនិយាយអំពីសេរីភាព យើងនិយាយអំពីសិទ្ធិមនុស្ស យើងនិយាយអំពីសកលភាវូបនីយកម្ម អ៊ីចឹងធ្វើឲ្យសម័យមួយដែលឆ្លងផុតទៅហើយនោះ ដែលប្រជាជាតិមួយចំនួនច្រើន មួយចំនួនធំមានជំនឿថា ជាមនោគមន៍វិជ្ជាដែលអាចយកមកប្រើដើម្បីផ្តល់ការរីកចម្រើនដល់មនុស្សលោកបាននោះ វាហួសសម័យ គេលែងត្រូវការ ពីព្រោះទស្សនៈថ្មី ការទទួលស្គាល់ថ្មីតាមភាពជឿនលឿនវាមកជំនួសដោយសេរី ប្រជាធិបតេយ្យសេរីនោះវិញ។

[១០:៤៤:១៣]

អ៊ីចឹងសួរថា តើលក្ខខណ្ឌសិទ្ធិមនុស្ស ឧទាហរណ៍ ការកម្រិតពីសេរីភាពក្នុងការបញ្ចេញមតិជាដើម នៅក្នុងរបបមួយដែលប្រកាន់បក្សតែមួយអាចឲ្យមានភាពទូលំទូលាយបានទេ? វាពិតជាអត់ទេ។ ខ្ញុំអាចលើកឧទាហរណ៍ជាក់ស្តែង នៅព្រះរាជាណាចក្រកម្ពុជាយើងនេះ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សួរថា តើព្រះរាជាណាចក្រកម្ពុជាកាលនោះ ជាកម្ពុជា មានឈ្មោះថា "កម្ពុជាប្រជាមានិត១" សួរថា តើបានផ្តល់នូវសេរីភាពគ្រប់បែបយ៉ាង ដូចអ្វីដែលយើងមានបច្ចុប្បន្ននេះទេ?

គឺអត់មានទេ គឺភ្លាមៗនោះវាស្ថិតនៅក្នុងបរិបទគឺការផ្លាស់ប្តូរ។ អ៊ីចឹង ចរន្តនៃការផ្លាស់ប្តូរវាអត់កើតមាននោះទេ វាមានជាការវិវត្តន៍បន្តិចម្តងៗ ដើម្បីឈានទៅរកអ្វីដែលប្រជាពលរដ្ឋមានជំនឿ ដូចយើងរហូតមកដល់ឆ្នាំ១៩៩៣ ទើបយើងមានរដ្ឋធម្មនុញ្ញដែលមានការទទួលស្គាល់នូវសិទ្ធិសេរីភាព និងសិទ្ធិនយោបាយ ហើយដែលទោសនយោបាយត្រូវបានលុបបំបាត់ទាំងស្រុង។ ដូច្នេះ ស្មារតីនេះ ស្មារតីនៃរដ្ឋធម្មនុញ្ញរបស់យើងនេះ វាកើតចេញពីសេចក្តីព្រមព្រៀងទីក្រុងបារីស ឆ្នាំ១៩៩១ ដែលបានផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការបង្កើតគណបក្សនយោបាយ និងចូលរួមក្នុងជីវភាពនយោបាយជាដើម។

ដូច្នេះ ក្នុងចំណុចនេះអ្វីដែលខ្ញុំចង់កត់សម្គាល់ជូនក្រុមប្រឹក្សាជំនុំជម្រះ គឺថាការអនុវត្តច្បាប់ក្នុងពេលបច្ចុប្បន្នទៅលើអំពើមួយដែលបានកើតឡើងឆ្លងសតវត្សរ៍នេះ វាធ្វើឱ្យមានបញ្ហាលំបាកជាខ្លាំង ពីព្រោះយើងមិនអាចយកទស្សនៈដែលមានបច្ចុប្បន្ននេះទៅអនុវត្តទាំងដុលនៅក្នុងរបបដែលកន្លងផុតទៅហើយជាច្រើនទសវត្សរ៍នោះទេ។

[១០:៤៧:០៩]

ក្រុមប្រឹក្សាជំនុំជម្រះជាទីគោរព! ទាក់ទងទៅនឹងលោក ខៀវ សំផន ខ្ញុំសូមធ្វើការកត់សម្គាល់ជូនក្រុមប្រឹក្សាដូចតទៅ៖

ពិតណាស់ហើយថា សហព្រះរាជអាជ្ញាក៏បានលើកបង្ហាញពីប្រវត្តិខ្លះៗរបស់លោក ខៀវ សំផន ហើយលោក ខៀវ សំផន ក៏បានឆ្លើយបញ្ជាក់ជូនអម្បាញ់មិញនេះផងដែរ ក៏ប៉ុន្តែនៅមានចំណុចជាច្រើនដែលយើងអាចមើលឃើញពីចំណុចល្អរបស់លោក ខៀវ សំផន ទាំងក្នុងជីវិតជាយុវវ័យរហូតមកដល់គាត់មានវ័យចាស់ជរានាពេលនេះ។

ចំណុចល្អអ្វីខ្លះទៅដែលយើងអាចពិភាក្សាបាន យើងមើលឃើញថា លោក ខៀវ សំផន គឺជាបញ្ញវន្តម្នាក់ គាត់បានសិក្សារៀនសូត្ររហូតដល់ថ្នាក់បណ្ឌិតនៅបរទេសទៀត។ លោក ខៀវ សំផន ក៏ធ្លាប់បានចូលរួមយ៉ាងសកម្មក្នុងជីវភាពកសាងប្រទេសនៅក្នុងសម័យសង្គមរាស្ត្រនិយម លោកក៏ត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ ហើយលោកក៏ត្រូវបានតែងតាំងជារដ្ឋលេខាធិការ ជាឋានៈដ៏ធំដ៏ខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាល។

[១០:៤៨:៣៥]

លើសពីនេះទៀត ការចូលរួមរំដោះជាតិនៅក្នុងចលនាកម្ពុជាប្រជាធិបតេយ្យមិនមែនជាចលនាដើម្បីបំផ្លិចបំផ្លាញកម្ពុជាទេនៅក្នុងសម័យនោះ។ ជាក់ស្តែងដូចលោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំ

ជម្រះអម្បាញ់មិញហើយថា លោកជាអ្នកទទួលបន្ទុកនៅក្នុងទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យជាមួយ និងសម្តេចនរោត្តម សីហនុ នៅពេលដែល បន្ទាប់ពីមានការធ្វើរដ្ឋប្រហារដោយ លន់ នល់ ក្នុងឆ្នាំ៧០។ ដូច្នេះ ការចូលរួមយ៉ាងសកម្មដើម្បីរំដោះប្រទេសជាតិដែលលោកយល់ថា ស្ថិតនៅក្រោមនឹមត្រួតត្រារបស់បរទេស គ្មានឯករាជ្យ វាជាទស្សនៈត្រឹមត្រូវក្នុងសម័យនោះ ពីព្រោះក្នុងនាមជាប្រជាជនម្នាក់នៃប្រទេសមួយ គំនិតស្នេហាជាតិ វាជាគំនិតដ៏ធំនៅក្នុងសម័យនោះ។ គេចូលចិត្តណាស់ គេពេញចិត្តណាស់ បើសិនជាបុគ្គលនោះស្រឡាញ់ជាតិ ជាអ្នកស្នេហាជាតិ ហើយរហូតមកដល់បច្ចុប្បន្ននេះក៏ទស្សនៈនៃការស្នេហាជាតិនេះក៏មិនទាន់សាបរលាបដែរ។ ដូច្នេះ ការចូលរួមរបស់លោក បានទទួលនូវផ្លែផ្កា បានទទួលជោគជ័យមែន ក៏ប៉ុន្តែមិនមែនមានន័យថា ដោយសារតែលោកម្នាក់ទើបបានទទួលជោគជ័យនោះទេ។

ជាចុងក្រោយនៅពេលដែលលោកទទួលបានជ័យជម្នះ ជាមួយនឹងក្រុមកម្ពុជាប្រជាធិបតេយ្យ តើអ្វីទៅដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា? សហព្រះរាជអាជ្ញា លោកបានបង្ហាញ និងគូសបញ្ជាក់អំពីចំណុចមួយចំនួន ឧទាហរណ៍ ដូចជាការជម្លៀសប្រជាពលរដ្ឋ ការបង្ខំឲ្យប្រជាពលរដ្ឋធ្វើពលកម្ម និងអំពើមួយចំនួនផ្សេងទៀត។ សួរថា តើអំពើទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន ឬ? ខ្ញុំជឿថា អស់លោកមិនភ្លេចទេថា លោក ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ បន្ទាប់ពីការលាលែងរបស់សម្តេចនរោត្តម សីហនុ។

[១០:៥១:៤៦]

ដូច្នេះ ក្នុងសម័យនោះ យើងអាចនិយាយបានថា កម្ពុជាមានប្រមុខរដ្ឋពីររូប មានអតីតប្រមុខរដ្ឋពីររូប។ ទីមួយ គឺសម្តេចនរោត្តម សីហនុ និងទីពីរ គឺលោក ខៀវ សំផន។ ខ្ញុំបាទសុំក្រុមប្រឹក្សាមេត្តាអនុញ្ញាតបង្ហាញប្រវត្តិរូបសង្ខេបមួយដែលធ្វើឡើងដោយ អ.វ.ត.ក ខាងព័ត៌មាន អ.វ.ត.ក។

បាទ, សូមមេត្តាលោកអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ,អនុញ្ញាត។ អញ្ជើញ!

**លោក គង់ សំអុន៖**

នៅក្នុងប្រវត្តិរូបនេះ គឺចេញផ្សាយដោយ អ.វ.ត.ក នៅក្នុងវែបសាយរបស់ អ.វ.ត.ក នេះឯង។ គឺមានសរសេរថា លោក ខៀវ សំផន។ ខ្ញុំសូមអានន្ទូវ១បន្ទាត់ដែលពាក់ព័ន្ធ គឺថា “នៅឆ្នាំ១៩៧៥ គាត់

ត្រូវបានតែងតាំងជាប្រមុខនៃរបបកម្ពុជាប្រជាធិបតេយ្យ”។

ខ្ញុំជឿថាក្រុមប្រឹក្សាជំនុំជម្រះនៃអង្គសវនាការ អាចយល់បាន ថាតើហេតុអ្វីបានជាខ្ញុំលើកចំណុចនេះ? វាជាចំណុចខ្វះខាតនៃការផ្សាយព័ត៌មានរបស់ អ.វ.ត.ក ដែលនិយាយខុស ឯកសារដែលបញ្ជាក់ថា លោក ខៀវ សំផន ត្រូវបានតែងតាំងជាប្រមុខរដ្ឋ ឬក៏ជាប្រធានគណៈប្រមុខរដ្ឋនោះមិនមែនឆ្នាំ១៩៧៥ នោះទេ គឺមួយឆ្នាំក្រោយមកទៀត បន្ទាប់ពីការលាលែងរបស់សម្ដេចនរោត្តម សីហនុ។

[១០:៥៤:៣១]

អ៊ីចឹង ខ្ញុំបាទសុំនៅពេលនេះដល់ក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីឲ្យមន្ត្រីជំនាញមេត្តាកែតម្រូវលើចំណុចនេះផង។ ចំណុចនេះ យើងមើលទៅហាក់ដូចជាតិចតួច វាមិនសំខាន់ គ្រាន់តែខុសលេខបន្តិចបន្តួចយើងអាចកែបាន ក៏ប៉ុន្តែសម្រាប់ខ្លឹមសារវាធំណាស់ វាអាចប៉ះពាល់ច្រើនទៅដល់ប្រវត្តិសាស្ត្រទាំងស្រុង។ ចំណុចនេះ ខ្ញុំសូមទាញការចាប់អារម្មណ៍ពីការទទួលខុសត្រូវរបស់លោក ខៀវ សំផន ក្នុងតួនាទីលោកជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំជឿថា សហព្រះរាជអាជ្ញាក៏បានឮហើយអំពីការថ្លែងរបស់លោក ខៀវ សំផន ថា ហេតុអីក៏មានតែគាត់ជាអតីតប្រមុខរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ នៅចំពោះមុខតុលាការនេះ ម៉េចក៏មិនយាងសម្ដេចនរោត្តម សីហនុ មកចូលនៅក្នុងតុលាការនេះផង។ តើវាខុសគ្នាយ៉ាងម៉េច?

ខ្ញុំជឿថា តុលាការនេះ មិនអាចកោះហៅសម្ដេច នរោត្តម សីហនុ ឲ្យមកឆ្លើយបំភ្លឺនៅទីនេះទេ។ ក៏ប៉ុន្តែ ខ្ញុំជឿថា សំណេររបស់ព្រះអង្គបានផ្សព្វផ្សាយជាច្រើនទាក់ទងទៅនឹងខ្សែជីវិតរបស់ព្រះអង្គកន្លងមក ដែលតុលាការអាចយកមកធ្វើជាការពិចារណាបាន។

[១០:៥៦:២៩]

នៅក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំដំបូង ព្រះអង្គគ្មានអំណាចអ្វីដើម្បីអារកាត់នៅក្នុងការគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យនោះទេ។ ចុះនៅពេលដែលលោក ខៀវ សំផន ឡើងជំនួស សួរថា តើមានអំណាចអ្វីខ្លះដែលកម្ពុជាប្រជាធិបតេយ្យផ្ដល់ឲ្យ? យើងមិនភ្លេចទេថា រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័ត ហើយក៏មានមាត្រាចែងអំពីគណៈ ប្រធានគណៈប្រមុខរដ្ឋនេះដែរ។ ក៏ប៉ុន្តែខ្ញុំសូមក្រុមប្រឹក្សាជំនុំជម្រះ និងអង្គសវនាការមេត្តាពិនិត្យទៅលើភាពជាក់ស្ដែងនៃតួនាទីរបស់លោក ខៀវ សំផន ក្នុងឋានៈជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ថាតើលោក

បានធ្វើអ្វីខ្លះ? មានអ្វីខ្លះសម្រាប់ប្រតិបត្តិនូវអំណាច ដែលផ្តល់ឲ្យដែរឬទេ?

[១០:៥៧:៥៦]

ខ្ញុំជឿថា សហព្រះរាជអាជ្ញានឹងមិនមានភស្តុតាងអ្វីដើម្បីបញ្ជាក់ថា ប្រធានគណៈប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ មានខុទ្ទការល័យ ឬមានការិយាល័យរបស់ខ្លួន ដើម្បីធ្វើការនោះទេ។

សម្រាប់ប្រមុខរដ្ឋដែលជាតំណាងរបស់ប្រទេស កន្លែងធ្វើការគ្មាន បុគ្គលិកសម្រាប់ជំនួយជាលេខាធិការដ្ឋានក៏គ្មាន មានតែអាត្មាឯងមួយអង្គឯង។ សួរថា តើអាចប្រតិបត្តិនូវអំណាចរបស់គាត់ នូវសិទ្ធិរបស់គាត់បានដោយរបៀបណា?

ទីពីរ ទាក់ទងនឹងតួនាទីមួយចំនួនទៀត ដែលសហព្រះរាជអាជ្ញាលើកថា លោក ខៀវ សំផន ជាប្រធានមន្ទីរនយោបាយ ម-៨៧០ ចំណុចនេះវាមានការយល់ច្រឡំច្រើននៅក្នុងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ យល់ច្រឡំយ៉ាងម៉េច? ម-៨៧០នេះ ត្រូវបានគេប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយយោងទៅលើការិយាល័យពីរ៖ ទីមួយគឺគណៈ៨៧០ មួយទៀត គឺមន្ទីរ ៨៧០។

ជួនកាលទៅ ឯកសារផ្សេងៗដែលសហព្រះរាជអាជ្ញានឹងបង្ហាញ នៅពេលសួរដេញដោល មានការច្របូកច្របល់គ្នាថាតើវាផ្ញើឯកសារទាំងអស់នោះ គេបញ្ជូនមក ម-៨៧០ ដែលជាមន្ទីរ ឬក៏ម-៨៧០ដែលជាគណៈ៨៧០។ ពីព្រោះគណៈ៨៧០ នេះ ដូចសហព្រះរាជអាជ្ញាបានបង្ហាញអំពីរចនាសម្ព័ន្ធអង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យហើយថា គឺជាតំណាងគណៈអចិន្ត្រៃយ៍។ គណៈអចិន្ត្រៃយ៍នេះ គឺជាអ្នកធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដឹកនាំនយោបាយប្រចាំថ្ងៃនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឯមន្ទីរ៨៧០វិញ គ្រាន់តែជាមន្ទីរនយោបាយមួយដែលមានបុគ្គលម្នាក់ជាអ្នកទទួលខុសត្រូវតាមដាន និងធ្វើការរាយការណ៍។ ហើយជារឿង អាចថាជារឿងចៃដន្យមួយនោះ លោក ខៀវ សំផន គាត់បានអង្គុយជាមួយអ្នកដែលទទួលខុសត្រូវនៅក្នុងមន្ទីរ៨៧០នេះ ម-៨៧០។ ពេលហ្នឹងហើយដែលធ្វើឲ្យមានការយល់ច្រឡំថា កន្លែងហ្នឹងជាការិយាល័យរបស់លោក ខៀវ សំផន។

[១១:០១:២៩]

ដល់តែពេលមន្ត្រីដែលផ្ញើឯកសារពីតាមភូមិភាគ ឬពីតំបន់មក វាអាចធ្វើឲ្យមានការយល់ច្រឡំ។ ចំណុចនេះងាយយល់ទេ។ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពុំមានឧបករណ៍ទំនើបប្រើដូចបច្ចុប្បន្ននេះផង មិនមានទេ។ ការបញ្ជូនសារគឺត្រូវសរសេរសំបុត្រ ត្រូវសរសេរវាយដាក់ទីឡូ ឬក៏សរសេរដៃមិនមានកុំព្យូទ័រទេ ហើយក៏មិនមានទូរស័ព្ទទំនើបទាក់ទងគ្រប់ច្រកល្ហកដូចយើងបច្ចុប្បន្ននេះដែរ។

អ៊ីចឹងសួរថាកម្រិតនៃទំនាក់ទំនងដើម្បីឲ្យមានសុក្រឹតនោះ វាមានកម្រិតណា? សុក្រឹតដែលខ្ញុំនិយាយនេះគឺថាអាចជឿថា វាមានកម្រិតណា។ ចុះមកឥឡូវនេះសម័យអ៊ីនធឺណេត យើងមើលនៅក្នុង អ.វ.ត.ក នេះប្រើប្រាស់ឧបករណ៍ទំនើបណាស់ ក៏ប៉ុន្តែគ្រាន់តែដកស្រង់ព័ត៌មានពីប្រវត្តិរូបរបស់លោក ខៀវ សំផន គឺធ្វើខុសបាត់ទៅហើយ។ ហើយឯកសារនេះមិនមែនអ្វីចម្លែកទេ មិនមែនជាឯកសារអាថ៌កំបាំងអីទេ គឺតុលាការបានផ្សាយជាសាធារណៈជាច្រើន ហើយក៏មានការដេញដោលនៅក្នុងតុលាការជាច្រើនដែរ អំពីប្រវត្តិរូបរបស់លោក ខៀវ សំផន នៅមានខុស ចុះទម្រាំនៅក្នុងសម័យដែលមានប្រព័ន្ធទំនាក់ទំនងដ៏អន់ថយនោះ វាខុសប៉ុនណា?

[១១:០៣:១០]

អ៊ីចឹងសួរថាតើឯកសារទាំងអស់នោះ សហព្រះរាជអាជ្ញានឹងលើកមកបង្ហាញនេះ ក្រុមប្រឹក្សាជំនុំជម្រះគួរជឿកម្រិតណា? នៅពេលសហព្រះរាជអាជ្ញាបង្ហាញអំពីការចោទប្រកាន់ ខ្ញុំពិនិត្យឃើញថាមានចំណុចខ្លះវាចូលជ្រៅ រហូតទៅដល់របៀបជាសេចក្ដីសន្និដ្ឋានចោទប្រកាន់ ជាសេចក្ដីសន្និដ្ឋានចុងក្រោយ ហើយក៏បានលើកនូវសម្ដីសាក្សីមួយចំនួន យកមកធ្វើជាអំណះអំណាងចំពោះទឡ្ហីករណ៍របស់លោកសហព្រះរាជអាជ្ញាដែរ។ ក៏ប៉ុន្តែសម្រាប់រូបខ្ញុំវិញ ខ្ញុំយល់ថា ការសួរដេញដោលនៅក្នុងនីតិវិធីដេញដោលពុំទាន់ត្រូវបានធ្វើនៅឡើយទេ។ ដូច្នេះ ខ្ញុំបាទសុំមិនឆ្លើយតបទៅនឹងការចង្អុលបង្ហាញទៅលើសម្ដីសាក្សីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាទេ។

ម្យ៉ាងទៀត នៅក្នុងនីតិវិធីតុលាការកម្ពុជាយើងនេះ ការធ្វើបើកសេចក្ដីសន្និដ្ឋានដោយមេធាវីការពារ ពុំធ្លាប់មានទេ។ នេះជាមធ្យោបាយល្អមួយដែរ បើសិនថ្ងៃក្រោយនីតិវិធីព្រហ្មទណ្ឌកម្ពុជារបស់យើង អាចត្រូវបានអនុញ្ញាតឲ្យមាននីតិវិធីបែបនេះ។ ដូច្នេះ ខ្ញុំយល់ថាបច្ចេកទេសនៅក្នុងការបង្ហាញបទចោទប្រកាន់វាអាចមានការខ្វះខាត អាចលើស អាចមានការខ្វះចន្លោះកើតមានឡើងជាយថាហេតុ។

[១១:០៥:៣៦]

ខ្ញុំបាទសូមលើកជាគ្រួសៗ ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ។ សហព្រះរាជអាជ្ញាបានលើកបង្ហាញថា លោក ខៀវ សំផន ប្រាកដជាអាចដឹងអំពីការសម្រេច ហើយដែលលោកនឹងបង្ហាញភស្តុតាង ឬក៏សាក្សីដើម្បីបញ្ជាក់ថា លោក ខៀវ សំផន ជាអ្នកទទួលខុសត្រូវមួយ ជាអ្នកទទួលខុសត្រូវម្នាក់ក្នុងចំណោមសហជនជាប់ចោទដទៃទៀត។ ក៏ប៉ុន្តែអ្វីដែលខ្ញុំបាទបានមើលឃើញនោះ វាផ្ទុយស្រឡះពីនេះ ដើម្បីអនុញ្ញាត ដើម្បីឲ្យការ ដើម្បីឲ្យភស្តុតាងអាច

ទទួលយកបាននៅក្នុងតុលាការនេះ វាត្រូវតែស៊ីសង្វាក់គ្នាទៅនឹងអំពើដែលមានកើតមានឡើង។

យើងទទួលស្គាល់ថា មានអំពើឃោរឃៅមួយចំនួនកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាថា លោក ខៀវ សំផន ជាប់ពាក់ព័ន្ធទទួលខុសត្រូវទៅលើអំពើនេះៗជារឿងមួយផ្សេងទៀត។ យើងរង់ចាំរហូតដល់ការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាឲ្យលើសពីវិមតិសង្ស័យ ដូចសហព្រះរាជអាជ្ញាបានលើកពីដើមដំបូងនៅពេលដែលលោកធ្វើបទបង្ហាញថា លោកជាអ្នកទទួលខុសត្រូវចំពោះការបង្ហាញភស្តុតាងនេះ។

[១១:០៧:៥១]

រឿងដែលលោក ខៀវ សំផន ដឹងឬក៏មិនដឹង នៅក្នុងការជម្លៀស វាជារឿងសំខាន់ រឿងសំខាន់។ ដោយសារអី? ដោយសារតែសហព្រះរាជអាជ្ញាបានប្រើទម្រង់នៃការចោទប្រកាន់មួយ គឺឧក្រិដ្ឋកម្មរួមសហឧក្រិដ្ឋកម្មរួម។ ដូច្នេះ បើសិនជាក្នុងក្រុមរបស់គាត់មាននរណាម្នាក់ជាអ្នកប្រព្រឹត្ត ហើយគាត់បានដឹង បានឮ ខ្ញុំនិយាយដោយខ្លី ខ្ញុំមិនលើកធាតុផ្សំទាំងអស់ទេ គាត់ក៏ត្រូវទទួលខុសត្រូវនៅក្នុងរឿងនោះដែរ។ អ៊ីចឹងដូចសហព្រះរាជអាជ្ញា គាត់បានលើកថា បាតដៃរបស់ជនជាប់ចោទមិនមានប្រឡាក់ឈាមទេ។ ប៉ុន្តែបានចិតនៅក្នុងសមុទ្រឈាម "*អូសិន អហ្វ ប្លាត់*"។ មិនប្រលាក់ឈាមនៅបាតដៃទេ ប៉ុន្តែបែរជាមានសមុទ្រឈាម មិនមែនថ្លុកឈាមទេ។

[១១:០៩:១៩]

ដូច្នេះ ការលើកឡើងរបស់សហព្រះរាជអាជ្ញានាពេលនេះ ខ្ញុំអាចមើលឃើញថា វាជាវោហារសាស្ត្រមួយ ដើម្បីបំប៉ោងឲ្យកាន់តែធំ ឲ្យកាន់តែច្រើនពីការទទួលខុសត្រូវរបស់ជនជាប់ចោទ។ បើយើងពិនិត្យទៅលើភាពជាក់ស្តែង សួរថា តើវាអាចមានទេ សមុទ្រឈាម? ពាក្យថាសមុទ្រវាមានទំហំប៉ុនណា? បឹងទន្លេសាបដ៏ធំ យើងហៅថាទន្លេ មិនទាន់ហៅសមុទ្រផង។ សួរថាតើឈាមវាអាចគ្របដណ្តប់ប៉ុនបឹងទន្លេសាបហ្នឹងទេ។

ដូច្នេះ ខ្ញុំគ្រាន់តែសូមកត់សម្គាល់ថា ជួនកាលទៅសហព្រះរាជអាជ្ញាគាត់បានប្រើវោហារសាស្ត្រដើម្បីធ្វើជាអំណះអំណាងនៅក្នុងការចោទប្រកាន់។ ការប្រើវោហារសាស្ត្រមិនមែនជាការបង្ហាញនូវការពិតទេ។ ប៉ុន្តែវាបង្ហាញនូវសិល្បៈនៃការប្រើប្រាស់ភាសា ហើយដែលយើងអាចរកឃើញនៅក្នុងល្ខោនកុន ជាដើម។

អ៊ីចឹង ខ្ញុំបាទសូមក្រុមប្រឹក្សាជំនុំជម្រះជួយកត់សម្គាល់ចំពោះវោហារសាស្ត្រទាំងឡាយ ដែល

សហព្រះរាជអាជ្ញាលើកឡើង ដោយពិនិត្យទៅលើភាពត្រឹមត្រូវ ភាពជាក់លាក់នៃពាក្យសម្តីដែលបានលើកធ្វើជាការចោទប្រកាន់នោះផង។

[១១:១១:២១]

ទាក់ទងទៅនឹងពលកម្មដោយបង្ខំ ខ្ញុំបាទបានស្តាប់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាថា លោក ខៀវ សំផន គឺបានដឹង ហើយបានចូលរួមនៅក្នុងទៅដល់ទីកន្លែងដែលធ្វើការនោះទៀត។ ប៉ុន្តែដូចលោក ខៀវ សំផន បានជម្រាបជូនពីព្រឹកមិញថា លោកបានធ្វើដំណើរទៅទីកន្លែងមួយចំនួនមែន ប៉ុន្តែមិនមែនទៅត្រួតពិនិត្យការងារក្នុងនាមជាប្រធាន ជានាយនោះទេ វាជាទស្សនកិច្ច ជាបែបទស្សនកិច្ច។ ជូនកាលលោកទៅជូនសម្តេចនរោត្តម សីហនុ ដើម្បីធ្វើទស្សនកិច្ចនៅតំបន់ណាមួយ។ អ៊ីចឹងសួរថា នៅពេលដែលមានទស្សនកិច្ចបែបនេះ គេអាចបង្ហាញនូវអ្វីដែលជារឿងពិត កើតឡើងពិតសម្រាប់ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យបែបនោះដែរទេ?

[១១:១២:៥១]

ប្រាកដជាមិនមែនទេ។ ប្រាកដជាអ្វីៗដែលលោក ខៀវ សំផន បានឃើញនៅពេលនោះ វាគឺជាឆាក វាគឺល្ខោនដែលគេរៀបចំឡើង។ គេរៀបចំឡើងដើម្បីឲ្យល្អ ដើម្បីឲ្យឃើញថា អ្វីៗដែលមាននៅក្នុងមូលដ្ឋាន វាជាការរីកចម្រើនជាវិជ្ជមាន។ អ៊ីចឹងសួរថា តើលោក ខៀវ សំផន អាចធ្វើអន្តរាគមន៍ដើម្បីកែតម្រូវដោយរបៀបណា?

ចំណុចនេះសហព្រះរាជអាជ្ញាប្រាកដជានឹងបង្ហាញថា លោក ខៀវ សំផន ជាប់ពាក់ព័ន្ធ ហើយអ្វីដែលកើតមាននៅពេលនោះគឺ លោក ខៀវ សំផន បានដឹង ហើយក៏អាចបានចូលរួមយ៉ាងសកម្មទៀតផង។ ក៏ប៉ុន្តែរឿងជាក់ស្តែងវាដូច្នោះទេ។

[១១:១៤:០៤]

កត្តាដែលយើងអាចបំបែកបានគឺ អំណាចរបស់គាត់។ អ្វីដែលគេចង់ឲ្យដឹង គេអាចឲ្យដឹង។ មិនមែនមានន័យថា គាត់អាចចង់ដឹងនូវអ្វីគ្រប់យ៉ាងទាំងអស់បានតាមចិត្តទេ។ ជាពិសេសទៀតលក្ខខណ្ឌនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺត្រូវទទួលខុសត្រូវការងាររបស់ខ្លួន បានន័យថា ការងាររបស់អ្នកណាអ្នកនោះអ្នកដឹង អ្នកនោះអ្នកធ្វើ អ្នកផ្សេងទៀតមិនអាចដឹងមិនអាចឮបានទេ។ កម្រិតបែបនេះ វាអាចធ្វើឲ្យអ្នកដទៃទៀតមិនហ៊ានយកចិត្តទុកដាក់ទៅលើអ្វីដែលមិនមែនជាភារកិច្ចរបស់ខ្លួន ពីព្រោះថាវាមិនមែនជាការងាររបស់ខ្លួន ហើយវាជាបញ្ហា វាជាគោលការណ៍ វាជាសេចក្តីសម្រេច ជាដើម។ល។

ដែលចេញពីថ្នាក់លើ អ៊ីចឹងអ្នកដែលអនុវត្តគឺត្រូវតែធ្វើទៅតាមកម្រិតដែលខ្លួនអាចធ្វើបាន។

ចំណុចមួយទៀត ទាក់ទងទៅនឹងការបោសសម្អាតកម្មាភិបាល ដូចសហព្រះរាជអាជ្ញាបានលើកពីសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ថានៅក្នុងមន្ទីរ ឬក្នុងតំបន់ ឬក៏ភូមិភាគរបស់ខ្លួន អ្នកដែលជាថ្នាក់ដឹកនាំ ជាកម្មាភិបាលនៅទីកន្លែងនោះ គឺមានសិទ្ធិកម្ទេចខ្មាំងនៅក្នុងបណ្តាញរបស់ខ្លួននៅក្នុងតំបន់របស់ខ្លួន។ ឧទាហរណ៍ នៅក្នុងក្រសួង ឬក៏មន្ទីរជាដើម។ ហើយលោកបានទម្លាក់កំហុសទៅលើការចាប់ខ្លួនរបស់ ប៉ង់ ឬក៏ ឌឿន ជាដើម ថាជាទង្វើរបស់លោក ខៀវ សំផន លោកដែលខ្ញុំនិយាយនេះ គឺសហព្រះរាជអាជ្ញា។ អ្វីដែលលោកបង្ហាញដោយផ្អែកតែទៅលើសេចក្តីសម្រេចនេះ ហើយថាលោក ខៀវ សំផន ជាអ្នកធ្វើ វាជារឿងមួយមិនអាចទទួលយកបានទេ។ ដោយសារអី? សេចក្តីសម្រេចនេះ បើសិនជាយើងមើលត្រឹមតែចំណងជើង យើងមើលទៅហាក់ដូចជាឃើញថាពាក្យកម្ទេច មែន។ ក៏ប៉ុន្តែបើពិនិត្យខ្លឹមសារទាំងអស់ វានឹងឃើញអ្វីប្លែកៗខុសពីនោះទៀត ។

[១១:១៧:០៨]

វាមិនមែនតែរឿងកម្ទេចទេ។ អ៊ីចឹងមិនមែនមានន័យថា នៅក្នុងភូមិភាគមួយ នៅពេលដែលបាត់នរណាម្នាក់ត្រូវគេសម្លាប់ ប្រធានភូមិភាគនោះ ត្រូវតែទទួលខុសត្រូវ ឬក៏ជាអ្នកដែលសម្លាប់គេនោះទេ។ វាត្រូវតែមានភស្តុតាងបញ្ជាក់ពីការប្រព្រឹត្ត មិនត្រឹមតែការប្រព្រឹត្តទេ រហូតដល់ចេតនាប្រព្រឹត្តទៀត ពីព្រោះវាជាធាតុផ្សំនៃបទល្មើសណាមួយដែលមាន។ ក៏ប៉ុន្តែខ្ញុំជឿថា ដូចលោកព្រះរាជអាជ្ញាសហព្រះរាជអាជ្ញាក៏បានលើកអំពីបទល្មើសមួយចំនួន ដែលជាបទល្មើសអកម្មផងដែរ វាអាចព្រមានសកម្មភាព។

សហព្រះរាជអាជ្ញាក៏បានលើកអំពីអំពើប្រល័យពូជសាសន៍ជនជាតិចាម អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម ហើយក៏ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមរបស់វៀតណាមផងដែរ-- ទៅលើជនជាតិវៀតណាមផងដែរ។ ចំណុចទាំងអស់នេះ អាចធ្វើការវាយតម្លៃបានរហូតណា ពិនិត្យទៅលើការដេញដោល ការបង្ហាញភស្តុតាង។

ដូច្នេះ ខ្ញុំបាទសូមមិនធ្វើការឆ្លើយតបទេ តែគ្រាន់តែសូមបង្ហាញជារួមថា អំពើប្រល័យពូជសាសន៍មិនមែនត្រឹមតែជាការសម្លាប់ទេ។ ការសម្លាប់មនុស្សម្នាក់មិនមែនជាបទល្មើសទេ មិនចង់និយាយថា មិនមែនសុទ្ធតែជាបទល្មើសទេ ហើយការសម្លាប់ក៏មិនមែនជាឃាតកម្មទាំងអស់ដែរ ហើយនៅគ្រប់ឃាតកម្មទាំងអស់ក៏មិនមែនជាអំពើប្រល័យពូជសាសន៍នោះដែរ។

អ៊ីចឹង ការពិនិត្យទៅលើពិរុទ្ធសតិ ទៅលើធាតុអត្តនោម័តិ និងធាតុសត្យានុម័តទាំងពីរដើម្បីបង្ហាញថា តើពិរុទ្ធភាពវាមានពិតប្រាកដឬអត់?

[១១:១៩:៣១]

ចំណុចមួយទៀត ដែលសហព្រះរាជអាជ្ញាលើក អំពីកម្ពុជាប្រជាធិបតេយ្យបានដាក់ប្រជាជនកម្ពុជាទាំងអស់ជាទាសករ។ ចំណុចនេះ យើងនិយាយទៅមិនអាចទទួលយកបានទាំងស្រុងទេ ពីព្រោះប្រជាជនកម្ពុជាទាំងអស់អ៊ីចឹងរួមទាំងលោក ខៀវ សំផន ខ្លួនឯងផងក៏ជាទាសករដែរ។ ក្នុងសម័យនោះ ប៉ុល ពត នៅរស់គាត់ក៏ជាជនជាតិខ្មែរដែរ អ៊ីចឹងគាត់ក៏ជាទាសករដែរ។ អ៊ីចឹងការនិយាយបែបនេះវាជាការនិយាយម៉ៅ និយាយសរុប ជាពាក្យសម្ដីដែលនិយាយមិនត្រូវ។ និយាយឲ្យត្រូវគឺត្រូវរកឲ្យឃើញ ឲ្យច្បាស់នៅចំនួនពិតប្រាកដ។ ឧទាហរណ៍ យើងនិយាយអំពីមរណភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំអត់បានស្ដាប់ឮសហព្រះរាជអាជ្ញាបង្ហាញថា តើមរណភាពទាំងអស់ ចំនួនទាំងអស់ដែលសហព្រះរាជអាជ្ញាបានលើកនោះ ជាមរណភាពកើតឡើងដោយសារស្អីខ្លះ? គឺមិនទាន់បានស្ដាប់នៅឡើយទេ។ ហើយខ្ញុំសង្ឃឹមថា សហព្រះរាជអាជ្ញានឹងធ្វើការបង្ហាញអំពីចំនួនជាក់លាក់។

[១១:២១:៣០]

ការស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានមូលហេតុច្រើនទៀត មិនមែនសុទ្ធតែជារឿងមនុស្សឃាត រឿងសម្លាប់ រឿងឃោរឃៅទេ។ ដូច្នេះការបាត់បង់ប្រជាពលរដ្ឋកម្ពុជានៅក្នុងសម័យនោះ វាមានកត្តាច្រើន បើយើងសរុបថាឲ្យតែអ្នកស្លាប់សុទ្ធតែជាអំពើរបស់កម្ពុជាប្រជាធិបតេយ្យវាអត់ត្រូវបាទវាអត់ត្រូវទេ។ ហើយម្យ៉ាងទៀត នៅពេលដែលសង្គ្រាម-- នៅពេលដែលរបបកម្ពុជាប្រជាធិប-តេយ្យដួលរលំប្រទេសកម្ពុជាស្ថិតនៅក្នុងភាពរញ៉េរញ៉ៃនៅឡើយទេ ពុំមានស្ថិតិ ទិន្នន័យអំពីចំនួនហ្នឹងច្បាស់លាស់ទេ។ អ្នកស្លាប់ដោយមូលហេតុផ្សេងៗខ្ញុំសរុបថា អ្នកស្លាប់ទាំងអស់ ហើយក៏មានអ្នករស់ខ្លះក៏អាចគេរាប់ចូលថាស្លាប់ដែរ។ គាត់រស់យ៉ាងម៉េច គឺគាត់រត់ឆ្លងដែន គាត់ក្លាយទៅជា ជន ភៀសខ្លួនទៅរស់នៅបណ្ដាប្រទេសទីបីនានា ប៉ុន្តែតួលេខវាត្រូវបាត់ចេញពីប្រទេសកម្ពុជា អ៊ីចឹងក៏សរុបថា ស្លាប់បាត់អស់ហើយ។ ត្រង់នេះ ខ្ញុំអាចសូមរំឭកទៅព្រឹត្តិការណ៍ដែលកើតឡើងចំពោះលោក ខៀវ សំផន ផ្ទាល់នៅពេលដែលលោករត់ចេញពីកម្ពុជានៅក្នុងឆ្នាំ១៩៦៧ ហើយដែលសហព្រះរាជអាជ្ញា បានលើកថាក្រោយពីបាត់ខ្លួនមួយរយៈ ស្រាប់តែចេញមកវិញ ហើយដូចគេហៅ-- គេឲ្យ ឈ្មោះ ថាជា ខ្មោចទាំងបីជាដើម។ ពីព្រោះរដ្ឋាភិបាលបានប្រកាសថាគាត់ស្លាប់ទៅហើយ តែទីបំផុត បែរជាគាត់នៅរស់។

អ៊ីចឹង ករណីនេះ វាដូចគ្នាដែរ ចំនួនប្រជាពលរដ្ឋដែលយើងសន្និដ្ឋាន ដោយគ្មានអំណះអំណាងច្បាស់លាស់ថាស្លាប់ តែការពិតគាត់មិនបានស្លាប់ទាំងអស់ ចំនួនអាចមិនច្រើន វាអាចមានចំនួនណាមួយជាក់លាក់ ហើយក៏ត្រូវស្វែងរកពីមូលហេតុនៃការស្លាប់របស់ប្រជាពលរដ្ឋ ឬក៏ជនរងគ្រោះនៅក្នុងសម័យនោះដែរ។

[១១:២៣:៥៦]

ចំណុចមួយទៀត ដែលសហព្រះរាជអាជ្ញាលើកអំពីការជំនុំជម្រះនេះ មិនមែនជាការសងសឹក ប៉ុន្តែវាជាការស្វែងរកការពិត ចំណុចនេះ ខ្ញុំជឿថាស្តាប់មើលទៅវាហាក់ដូចជាល្អម្យ៉ាង ពីរោះម្យ៉ាង ក៏ប៉ុន្តែបើយើងពិនិត្យទៅលើធាតុពិតនៃការស្វែងរកយុត្តិធម៌ក្នុងករណីព្រហ្មទណ្ឌវាអត់ត្រូវ។ វាអត់ត្រូវយ៉ាងម៉េច? បើសិនជាយើងមិនសងសឹក យើងស្វែងរកការពិត វាគួរតែបង្កើតគណៈកម្មការស្វែងរកការពិតដូចនៅអាហ្វ្រិកខាងត្បូងនោះ *ទ្រូសខំមិស្សិន* អ៊ីចឹងទៅ។ វាអត់មានការកាត់ទោស អត់មានការដាក់គុក ដាក់ច្រវាក់អីទេ ក៏ប៉ុន្តែនៅទីនេះ ទោសព្រហ្មទណ្ឌវាមាន។ ក្នុងគោលការណ៍នៃការដាក់ទោសព្រហ្មទណ្ឌ គោលការណ៍ធំមួយក្នុងចំណោមទាំងបួន គឺការសងសឹក វាមានការសងសឹកនៅក្នុងហ្នឹងហើយ។ ក៏ប៉ុន្តែការសងសឹកបែបនោះគេហៅថា ធ្វើឡើងដោយស្របច្បាប់ មិនមែនការសងសឹកយកកម្លាំងផ្ទាល់ខ្លួនទៅឆ្លើយតបទៅនឹងអំពើណាមួយនោះទេ។

[១១:២៥:២២]

ទាក់ទងទៅនឹងការបង្ហាញភស្តុតាងដែលថា លោក ខៀវ សំផន បានចូលរួមប្រជុំនៅក្នុងគណៈអចិន្ត្រៃយ៍ជាច្រើន និយាយទៅក្នុងចំណោម១៩ កំណត់ហេតុដែលនៅសល់លោកមានវត្តមាន១៤ ហើយក្នុងតារាងបង្ហាញរបស់សហព្រះរាជអាជ្ញាគឺឃើញថា វត្តមានរបស់លោកគឺស្ថិតនៅក្នុងលំដាប់ទីបី។ អ៊ីចឹងមានន័យថាជាវត្តមានខ្ពស់ច្រើន ដែលសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានទាញហេតុផល ថាអ៊ីចឹង លោកគួរតែដឹងហើយលោក ខៀវ សំផន ហ្នឹងគួរតែដឹងហើយ អំពីការសម្រេចនានារបស់គណៈអចិន្ត្រៃយ៍នោះ ពីព្រោះលោកបានចូលរួមយ៉ាងច្រើន ប៉ុន្តែការពិតវាមិនមែនអ៊ីចឹង។

ខ្ញុំសូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យដោយយកចិត្តទុកដាក់ចំពោះកំណត់ហេតុនីមួយៗថា តើកំណត់ហេតុទាំងអស់នោះ វាជាកំណត់ហេតុពិតប្រាកដ ឬក៏ជាកំណត់ហេតុក្លែងក្លាយ? មូលហេតុអី? កំណត់ហេតុទាំងអស់នោះភាគច្រើនដែលខ្ញុំបានឃើញ គឺគ្មានការចុះហត្ថលេខាទទួលស្គាល់ថាអ្នកណាជាអ្នកធ្វើពិតប្រាកដទេ។ គ្មានលក្ខណៈបញ្ជាក់អត្តសញ្ញាណ គ្មានលក្ខណៈបញ្ជាក់ពីភាពត្រឹមត្រូវ គ្រាន់

តែជាសំណេរមួយនៅលើដាក់ទីឡូ ដែលប្រើដាក់ទីឡូ អ៊ីចឹងវាអាចមានការកែបន្ថំបាន វាអាចមានការធ្វើក្រោយបាន អានេះវាជាចំណុចវិមតិសង្ស័យនៅក្នុងការបង្ហាញភស្តុតាង បើសិនជាមានវិមតិសង្ស័យបែបនេះនៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង និងច្បាប់របស់កម្ពុជាគឺត្រូវជាប្រយោជន៍របស់ជនជាប់ចោទ។ បានន័យថា ការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាមិនបានគ្រប់គ្រាន់ទេ មិនបានពេញលេញទេ។

[១១:២៧:៥៩]

ជាសរុប ខ្ញុំបាទសូមទាញការចាប់អារម្មណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យទៅលើស្ថានភាពមួយដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ស្ថានភាពនោះគឺភាពរញ៉េរញ៉ៃគ្មានសណ្ដាប់ធ្នាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងដំណាក់កាលដំបូង នៅពេលដែលទទួលបានជ័យជម្នះភ្លាមថា តើភាពរញ៉េរញ៉ៃគ្មានសណ្ដាប់ធ្នាប់នេះ វាធ្វើឲ្យប៉ះពាល់ដល់សង្គមទាំងមូលដូចម្ដេច? ហេតុអីបានមានភាពរញ៉េរញ៉ៃ ហេតុអីបានៗគ្មានសណ្ដាប់ធ្នាប់? ខ្ញុំជឿថាអង្គសវនាការទាំងមូលបានជ្រាបច្បាស់ថា ជ័យជម្នះរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាជ័យជម្នះដោយសង្គ្រាម មិនមែនជ័យជម្នះដោយការចរចាទេ។

[១១:២៩:១០]

អ៊ីចឹង វាមានកម្លាំងបដិបក្ខប្រឆាំងគ្នានៅក្នុងប្រទេសកម្ពុជា ហើយដែលអាចកាប់សម្លាប់គ្នាដោយការគុំកួន ដោយការស្អប់ ដោយការសងសឹកនេះមិនខាន។ ខ្ញុំសូមលើកឧទាហរណ៍ពីឆ្នាំទៅ នៅកោះពេជ្រ នៅពេលបុណ្យអុំទូក ២០១០ គ្រាន់តែភាពរញ៉េរញ៉ៃគ្មានសណ្ដាប់ធ្នាប់របស់ប្រជាពលរដ្ឋក្នុងតែមួយរយៈ តែមួយពព្រិចភ្នែកធ្វើឲ្យប្រជាពលរដ្ឋខ្មែរយើងទទួលសោកនាដកម្មយ៉ាងធ្ងន់ គឺមានមនុស្សជាច្រើនរយនាក់ ជាង៣០០នាក់ បានស្លាប់ដោយសារតែការជាន់គ្នា។ នេះគ្រាន់តែជាភាពរញ៉េរញ៉ៃតែក្នុងមួយកន្លែងតូចផង ចុះទម្រាំតែភាពរញ៉េរញ៉ៃទូទាំងប្រទេស សួរថា វិបត្តិនៃការគ្រប់គ្រងមនុស្សមិនបានល្អនេះ វាធ្វើឲ្យមានភាពរញ៉េរញ៉ៃនេះ វាធំប៉ុនណា? ខ្ញុំចាំបាននូវព្រឹត្តការណ៍អន្តរជាតិជាច្រើនឧទាហរណ៍ យើងមិនបាច់និយាយដល់សង្គ្រាមទេ សូម្បីតែទឹកជំនន់ ឬក៏រញ្ជួយផែនដី នៅពេលដែលមានព្រឹត្តិការណ៍អ៊ីចឹងកើតឡើង មនុស្សលែងគ្រប់គ្រងគ្នាកើតហើយ។ ចេញទៅដណ្ដើមអីវ៉ាន់គ្នាទោះបីជារបស់គេអីក៏ដោយ វាមាន-- ដោយសារអី ដោយសារស្ថានភាពនៃការគ្រប់គ្រងមនុស្សវាមិនកើត។ អ៊ីចឹងវានាំឲ្យមានអំពើផ្សេងៗដែលអាចកើតមានឡើង វារួមទាំងអំពើស្របច្បាប់ និងមិនស្របច្បាប់ដែលយើងហៅថាជាអំពើឃោរឃៅហ្នឹងក៏ដោយ វាកើតមានអ៊ីចឹង។ សូម្បីតែនៅសហរដ្ឋអាមេរិកខ្ញុំចាំណាំ មានព្យុះមួយឈ្មោះ ខាត់ទ្រីណា បានធ្វើឲ្យផ្ទះសម្បែងរបស់ប្រជាជនអាមេរិក ដែល

ស្ថិតនៅក្នុងតំបន់ហ្នឹងប៉ះពាល់ខ្មេច ខូចខ្មេចខ្ចី ហើយនៅពេលនោះអ្នកដែលថតវីឌីអូបាន-- អ្នកដែលយកព័ត៌មានជាដើម ធ្វើសេចក្តីរាយការណ៍ គឺឃើញមានភាពរញ៉េរញ៉ៃ ការដណ្តើមគ្នា ដណ្តើមយកអីវ៉ាន់របស់អ្នកដទៃ ការចាប់រំលោភក៏មាន គឺមានព្រឹត្តិការណ៍ច្រើនណាស់។ ហ្នឹងនៅសហរដ្ឋអាមេរិកផង ហើយក្នុងសម័យពេលថ្មីៗនេះផង ចុះទម្រាំ ៣០ឆ្នាំជាងមុន ការគ្រប់គ្រងមនុស្សមិនទាន់មានឧបករណ៍ទំនើបសម្រាប់គ្រប់គ្រង។ អ៊ីចឹងវាមានការលំបាកច្រើន។

[១១:៣២:១៧]

ភាពរញ៉េរញ៉ៃដែលខ្ញុំនិយាយនេះ វាបង្កវាបង្កើតជាព្យសនកម្មផ្សេងៗ តាំងពីការសម្លាប់ ការចាប់រំលោភ ឬក៏ជាបទល្មើសផ្សេងៗទៀត ដោយសារតែរដ្ឋាភិបាលថ្មីនៃរបបកម្ពុជាប្រជាធិបតេយ្យមិនអាចគ្រប់គ្រងបាននូវស្ថានការណ៍ភ្លាមៗ។ វាអាចមានបញ្ហាដោយសារសមត្ថភាពរបស់មន្ត្រី ឬជាកម្មាភិបាលក្នុងសម័យនោះ ឬក៏វាគ្មានធនធានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រទេសជាតិនៅពេលនោះ។ ឧទាហរណ៍ ពុំមានយន្តការសម្រាប់ពិនិត្យ ឬក៏ផ្តល់សេវា ជួយដល់អំពើបះបោល ឬក៏ភាពគ្មានសណ្តាប់ធ្នាប់នៅពេលនោះ។ អ៊ីចឹងភាពរញ៉េរញ៉ៃនេះ វាបង្កព្យសនកម្មថែមទៀតទៅលើការគ្រប់គ្រង ដែលអាចចាត់ទុកថា ពុំមានអង្គការចាត់តាំងត្រឹមត្រូវ។ ពាក្យថា "អង្គការចាត់តាំង" ដែលខ្ញុំនិយាយនេះ គឺសំដៅដល់រចនាសម្ព័ន្ធពីថ្នាក់លើដល់ថ្នាក់មូលដ្ឋាន។

[១១:៣៣:៤៣]

ដូច្នេះ ជាចុងបញ្ចប់ ខ្ញុំបាទសូមលើកសំណូមពរជូនក្រុមប្រឹក្សាជំនុំជម្រះពិនិត្យទៅលើភស្តុតាងក៏ដូចជាសាក្សី ដែលសហព្រះរាជអាជ្ញានឹងលើកយកមកបង្ហាញនៅពេលសវនាការបន្តបន្ទាប់ទៀតនេះ ដោយយកចិត្តទុកដាក់ និងពិនិត្យទៅលើភាពលម្អិតនៃភស្តុតាងទាំងនោះផង។ ថាតើវាជាភស្តុតាងពិតប្រាកដដែលអាចទទួលយកបាន ឬមួយក៏ជាភស្តុតាងដែលមិនអាចយកជាការបាន ឧទាហរណ៍ដូចជាភស្តុតាងដែលចេញមកអំពីការបង្ខំឲ្យឆ្លើយសារភាព។ ឧទាហរណ៍ ដូចជាមាននៅក្នុងមន្ទីរស-២១ ជាដើម ដែលពុំមានការត្រួតពិនិត្យច្បាស់លាស់ថា អ្នកដែលសរសេរបន្សល់ទុកនូវឯកសារទាំងអស់នោះ គឺបានសរសេរនូវអ្វីដែលរឿងពិតរបស់ខ្លួននោះឡើយ។

បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

មេធាវីអន្តរជាតិ តើមានបំណងក្នុងការធ្វើសេចក្តីសន្និដ្ឋានតបដែរឬទេ?

**លោក ហ្សាក់ វែកហ្សេស៖**

ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទេ។

ជាដំបូងសូមគោរពលោកប្រធាន សូមគោរពអង្គចៅក្រមទាំងមូល សូមគោរពសហព្រះរាជអាជ្ញា សូមគោរពសាធារណជនកម្ពុជាទាំងអស់។

ខ្ញុំចង់និយាយអំពីដល់ការមរណភាពដែលយើងបានបំភ្លេចចោលនៅក្នុងការកាត់ក្តីនេះ ហើយនិងការសម្លាប់មនុស្សដោយសារតែការទម្លាក់គ្រាប់បែកអាមេរិកាំងនៅលើប្រទេសកម្ពុជា ហើយនិងពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែកនៅក្នុងប្រទេសផ្សេងៗទៀតនៅក្នុងសង្គ្រាមពិភពលោក គឺថាវា សង្គ្រាមនេះបានមានទំហំធំធេងណាស់។ ដូច្នេះ ខ្ញុំសូមបង្ហាញនូវការគិតថា គឺគិតទៅដល់កុមារដែលបានកើតឡើងបន្ទាប់ពីសង្គ្រាម ហើយដែលទទួលរងនូវឪពុកម្តាយដែលមានការពិការជាដើម។ ខ្ញុំចង់និយាយថា គឺដើម្បី-- ខ្ញុំនិយាយបែបនេះ ដើម្បីឲ្យមតិសាធារណៈយល់ថា ការស្លាប់នេះថាមិនត្រូវបានបំភ្លេចទេ ហើយខាងការពារក្តីក៏បានគិតទៅដល់មរណភាពទាំងអស់នេះ។ ហើយសូម្បីតែខាងសហព្រះរាជអាជ្ញាក៏មិនបានគិតទៅដល់បញ្ហានេះដែរ។

[១១:៣៦:២៦]

ហើយខ្ញុំបានស្តាប់សម្តីជាច្រើនរបស់សហព្រះរាជអាជ្ញា គឺលោក លោកស្រីសហព្រះរាជអាជ្ញាទាំងពីរ ហើយគឺថាវាជាប្រលោមលោកមួយដ៏ល្អណាស់ ដែលថាសរសេរបានយ៉ាងល្អមែនទែនទៅលើអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជា។ ក៏ប៉ុន្តែប្រលោមលោកនេះគឺថា ផ្អែកតែទៅលើរបាយការណ៍ ឬក៏បទយកការណ៍របស់អ្នកសារព័ត៌មាន ហើយនិងអត្ថបទដែលអនាមិក ហើយដូចដែលលោក ខៀវ សំផន បាននិយាយអ៊ីចឹង គឺថាពួកគាត់មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ គឺថាវាខុស វាប្រឆាំងទៅនឹងជនជាប់ចោទ។ ហើយនៅចុងក្រោយនោះ លោក លោកស្រីសហព្រះរាជអាជ្ញា គឺថា បាននិយាយបំប្លែងការពិតទាំងស្រុង គឺថាចំពោះគាត់ការពិតនោះគឺមានន័យថា ប្រជាជនទាំងមូល ត្រូវបានជិះជាន់គាបសង្កត់ទៅដោយបុគ្គលទាំងបីដែលនៅកំពុងតែអស់លោកទាំងអស់គ្នានេះ។

ដូច្នេះគឺអ្វីទាំងអស់ គឺអាស្រ័យទៅលើជនទាំងបីរូបនេះ គឺថាវាគ្មានទំនាក់ទំនង គ្មានការទាក់ទងទៅនឹងការពិតអ្វីបន្តិចទាល់តែសោះ។ ហើយប្រសិនបើយើងស្តាប់នូវសក្ខីកម្មផ្សេងទៀត គឺថា ដែលពិភពលោកទាំងមូលទទួលស្គាល់ គឺដូចឧទាហរណ៍ដូចជាលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ អ៊ីចឹងដែរ គឺគាត់ជា

អ្នកស្រាវជ្រាវបារាំង គឺថា គាត់បានធ្វើការស្រាវជ្រាវជាច្រើនទៅលើបញ្ហាខ្មែរក្រហម ហើយគាត់បានបោះពុម្ព សៀវភៅមួយដែលពិភពលោកទាំងមូលទទួលស្គាល់។ ប៉ុន្តែគឺសហព្រះរាជអាជ្ញាគាត់អត់បានដឹងទេ។ នៅក្នុងសៀវភៅនេះគាត់បានរៀបរាប់ទៅលើព្រឹត្តិការណ៍ពីរ ពាក់ព័ន្ធទៅនឹងដំណើរការនៃការជំនុំជម្រះក្តី គឺគាត់បានចូលរួមនៅក្នុងការជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញ គាត់ក៏ត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញដែរ។ ហើយគាត់បានបង្ហាញនូវរឿងរ៉ាវផ្សេងៗពាក់ព័ន្ធទៅនឹងទាហាននាសម័យខ្មែរក្រហម។ ខ្ញុំអត់មានសៀវភៅនេះនៅនឹងមុខទេ គឺថាពួកអ្នកខ្លះមកពីតំបន់ខ្លះនោះ គឺថាមានភាពសាហាវឃោរឃៅណាស់ ហើយមានអ្នកជំងឺ មានអី ហើយអ្នកខ្លះ គឺគាត់មានលក្ខណៈជាមនុស្សធម៌ គឺគាត់មានកូននៅក្នុងដៃ។

[១១:៣៨:៥០]

ដូច្នេះ នៅសម័យនោះ គឺថាវាមានលក្ខណៈសាហាវឃោរឃៅ គឺថាបានបញ្ជាទៅឲ្យទាហាន គឺថាមិនមែនអ៊ីចឹងទេ គឺគាត់ប្រព្រឹត្តទៅដោយលក្ខណៈខ្លួនឯង គឺមិនមានការបញ្ជាណាឲ្យគាត់ធ្វើឲ្យសាហាវឃោរឃៅទាំងអស់នោះទេ គឺទាហានទាំងអស់នោះគាត់ប្រព្រឹត្តទៅដោយខ្លួនឯងអំពីភាពសាហាវឃោរឃៅរបស់គាត់ទាំងអស់នោះ។

ហើយទីពីរទៀត លោកប៊ីហ្ស៊ូ គឺគាត់បាននិយាយផងដែរថា គាត់ក៏មានការទទួលនូវការសង្គ្រោះពីខ្មែរក្រហមដែរ។ ដូច្នេះគាត់បានដឹងច្បាស់ពីស្ថានភាពកាលពីសម័យខ្មែរក្រហម ហើយតាម៉ុកដែលជាមេខ្មែរក្រហម គឺ ចំពោះតាម៉ុកនោះគឺថា ប៊ីហ្ស៊ូ នេះគឺគាត់ជាគិញរបស់ សេ.អ៊ី.អា គាត់យល់ថាជា-- ហើយ ប៊ីហ្ស៊ូ គាត់បានបដិសេធ គាត់បានតតាំងទៅនឹងការចោទនោះ ហើយជាចុងក្រោយគឺគាត់បានរួចជីវិតរបស់គាត់។

[១១:៣៩:៤៩]

ដូច្នេះគាត់គឺជាសាក្សី ដែលមិនអាចប្រកែកបាន គឺជាសាក្សីដ៏សំខាន់ដែរនៅក្នុងរឿងក្តីនេះ ហើយវាសម្រាប់នូវរឿងរ៉ាវដែលសុបិនអាក្រក់ទាំងអស់នោះ។ ដូច្នេះយើងមិនអាចចោទទៅលើតែអ្នកទាំងបីនេះបានទេ វាមិនមែនជាការពិតនោះទេ។ ដូច្នេះខ្ញុំមានទស្សនៈថា សហចៅក្រមស៊ើបអង្កេតនេះ គឺគាត់ថាចង់ធ្វើម៉េចដើម្បីកាត់ទោសជនជាប់ចោទទាំងអស់នេះ។ គឺថាអ្នកទាំងបីនេះគឺកំពុងតែនៅទីនេះហើយ ហើយទាំងអស់នេះ គឺជាការបំផ្លើស គឺជាការច្នៃប្រឌិត ជាការបំភាន់ថែម វាមិនមែនជាការពិតនោះទេ គឺយើងត្រូវតែធ្វើយ៉ាងម៉េចវិនិច្ឆ័យទៅរកការពិត យើងធ្វើទៅតាមអង្គហេតុដែលកើតឡើងពិត

ប្រាកដ។

បាទ អ៊ីចឹងខ្ញុំសូមបញ្ចប់នៅពេលបន្តិចទៀតនេះ ហើយយើងដឹងទាំងអស់គ្នាហើយថា យើងបានរស់នៅក្នុងភាពប្របូកច្របល់ នៅក្នុងភាពលំបាកដែលមានតែមួយគត់នៅប្រទេសកម្ពុជា គឺថាមានរដ្ឋប្រហារយោធាមួយកាលពីសម័យនោះ ហើយរដ្ឋប្រហារនោះបាននាំឲ្យរបបនោះក្លាយទៅរបបផ្តាច់ការហ្វាស៊ីស រួចហើយបានបង្កើតជារបបសាធារណរដ្ឋ ហើយវាគឺជាការធ្វើរដ្ឋប្រហារនោះ គឺថាបានទម្លាក់សម្តេចសីហនុ គឺសម្តេចសីហនុត្រូវបានទម្លាក់ដោយ លន់ នល់ ហើយនៅសម័យនោះ គឺថាលោកខៀវ សំផន ដែលកូនក្តីរបស់ខ្ញុំនោះ គាត់បានធ្វើដំណើរចាកចេញពីភ្នំពេញ ដើម្បីចូលទៅក្នុងព្រៃតស៊ូ ហើយគាត់គឺជាជនកុម្មុយនីស្តក្រោមដី ដើម្បីតស៊ូប្រឆាំងនឹងរបបលន់ នល់។ គឺថាហើយខាង លន់ នល់ នោះគឺបានដក គឺបានសម្រាតខោអាវរបស់គាត់ឲ្យដើរនៅក្នុងទីលានសាធារណៈ ធ្វើឲ្យគាត់អាម៉ាស់មែនទែន។ ដូច្នេះ គាត់បានរត់ចូលទៅក្នុងព្រៃ ដើម្បីតស៊ូប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋ។

[១១:៤២:០២]

ដូច្នេះយើងឃើញថា យើងមានឃើញការតវ៉ារបស់វៀតណាម ហើយមានការតវ៉ាពីខាងវៀតណាម មានការទម្លាក់គ្រប់បែករបស់អាមេរិកជាដើម។ ដូច្នេះ ក្នុងលក្ខខណ្ឌទាំងអស់នេះហើយ យើងអាចឃើញថា យើងជាមនុស្ស យើងមានភាពទន់ខ្សោយរបស់យើង យើងអាចប្រព្រឹត្តនូវកំហុស ឬក៏អាចប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ក៏ប៉ុន្តែគឺយើងមិនមែនជាបិសាចទេ អ្នកណាដែលគិតថា គឺជនជាប់ចោទជាបិសាចជាជនអាក្រក់នោះ វាគ្រាន់តែជារឿងនៅក្នុងអក្សរសិល្ប៍ នៅក្នុងប្រលោមលោកតែប៉ុណ្ណោះ។

[១១:៤២:៣២]

ដូច្នេះ អំណាចខ្មែរក្រហមគឺបានចូលមក តើអ្នកណាដែលជាអ្នកនាំឲ្យមានខ្មែរក្រហមកាន់អំណាច? គឺដោយមានការចលនាតស៊ូ ចលនាតស៊ូរបស់ប្រជាជនដែលនាំឲ្យខ្មែរក្រហមចូលកាន់អំណាចនោះ។ ហើយមិនមែនជាការរំលំក្នុងរបបខ្មែរក្រហមដោយកម្លាំងប្រជាជនទេ គឺជាការរំលំដោយការជ្រៀកជ្រែកចូលរបស់កងទ័ពបរទេស។ ដូច្នេះ វាមិនមែនជារបបមួយដែលថាគ្មានការគាំទ្រពីប្រជាជនទេ។ ដូច្នេះ អ្វីទាំងអស់នេះ គឺជាការកែច្នៃ គឺជាការរៀបចំមួយ ដើម្បីឲ្យមានការយល់ខុសទាំងអស់គ្នា។

ដូច្នេះ ខ្ញុំ លោក លោកស្រីចៅក្រមទាំងអស់ជាចុងក្រោយនេះ ខ្ញុំចង់និយាយថានៅក្នុងភាពច្របូកច្របល់ នៅក្នុងភាពវិបល្លាសចលាចលនេះ គឺមនុស្សអាចប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយនេះមិនមែនជាហេតុផលដែលត្រូវចោទថា គាត់ទៅជាបិសាចនោះទេ។ គឺថាប្រទេសកំពុងតែស្ថិតនៅក្នុងភាពរញ៉េរញ៉ៃ

ដូច្នេះវាមិនមែនជារឿងមួយដែលត្រូវតែចោទប្រកាន់ទៅលើជនទាំងអស់នេះទេ។ ហើយយើងគ្មានអ្វីដែលត្រូវចោទប្រកាន់ទៅលើគាត់ទាំងអស់នោះទេ។ ដូច្នេះឧទាហរណ៍ដូចជាប្រមុខរដ្ឋទាំងពីរនេះ គឺថាយើងគ្មានអីដែលត្រូវបន្ទោសគាត់ទេ ដូចជាសម្តេចសីហនុ ហើយនិងលោក ខៀវ សំផន ជាដើម។

[១១:៤៣:៥០]

ដូច្នេះ អ្នកទាំងពីរនេះ យើងមិនអាចចោទប្រកាន់គាត់ថាជាបិសាចទេ វាជារឿងមួយគួរឲ្យអស់សំណើចណាស់។ ដូច្នេះលោក លោកស្រីទាំងអស់គ្នា គឺសូមឲ្យលោក លោកស្រីកាត់សេចក្តីដោយយកចិត្តទុកដាក់ទៅលើការពិត ហេតុការណ៍ដែលមានកើតឡើងការពិត ហើយយើងមិនត្រូវគិតថាអ្នកទាំងបីនេះគឺចង់ឲ្យប្រជាជនស្លាប់ទេ។ វាមិនមែនជាការពិតនោះទេ សូមឲ្យយើងទាំងអស់គ្នា មានហេតុផលទាំងអស់គ្នា ហើយខ្ញុំសូមបញ្ចប់ដោយនិយាយឃ្លា ឃ្លាមួយរបស់ជនជាតិបរទេសមួយ គឺរបស់ណាប៉ូឡេអ៊ុង ដូច្នេះលោក លោកស្រីសហព្រះរាជអាជ្ញាអ្វីដែលជាមានលក្ខណៈហួសហេតុនោះ គឺថាមិនមានលក្ខណៈមិនត្រឹមត្រូវតែប៉ុណ្ណោះ ហើយវាគ្មានផលប្រយោជន៍ គ្មានការពិតអីទាំងអស់។

បាទ, សូមអរគុណ។ ខ្ញុំគិតថា ខ្ញុំមិននិយាយអ្វីដែលវាហួសហេតុពេកទេ។ សូមអរគុណ។

[១១:៤៤:៥០]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។ ហើយដល់ពេលនេះកិច្ចដំណើរការនីតិវិធីស្តាប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ចំពោះជនជាប់ចោទដោយសង្ខេប ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា និងការឆ្លើយតប ដោយសង្ខេបដោយជនជាប់ចោទ និង/ឬ មេធាវីការពារក្តីបានដល់ទីបញ្ចប់ហើយ ហើយក៏ដល់ពេលសមល្មមនឹងត្រូវសម្រាកហើយដែរសម្រាប់សវនាការថ្ងៃនេះ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការ--

សូមអញ្ជើញ!

[១១:៤៥:៣៤]

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឡើងមកនេះ គឺថាមិនមានអីការឆ្លើយតបទៅខាងមេធាវីការពារក្តី ក៏ដូចជាសេចក្តីថ្លែងការណ៍ទេ ប៉ុន្តែខ្ញុំឡើងមកនេះ គឺដើម្បីបញ្ជាក់បន្ថែមនូវអ្វីដែលក្រោយពីបានស្តាប់ថា ថ្ងៃអនាគតខាងមុខនេះ នៅពេលសវនាការអាទិត្យក្រោយមួយទៀតនេះ តើយើងចង់បានអ្វី?

ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ក៏ដូចជាលោក លោកស្រីចៅក្រមទាំងអស់ដើម្បីបញ្ជាក់ពីបញ្ហានេះ។ ដូច្នេះ ក្រោយពីបានស្តាប់ការថ្លែងការណ៍របស់ជនជាប់ចោទទាំងបី ក៏ដូចជាការឆ្លើយតបរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន ដែរ គឺថាយើងបានជួបប្រទះនូវបញ្ហាមួយ គឺថានៅក្នុងកិច្ចប្រជុំមួយជាមួយនឹងមន្ត្រីជាន់ខ្ពស់កាលពីថ្ងៃសុក្រ អាទិត្យមុនហ្នឹង គឺថាក្រុមមេធាវីការពារក្តី នួន ជា ហើយនិង ខៀវ សំផន បានចូលរួម ហើយនិងលើកឡើងពីបញ្ហាពួកគេមិនអាចឆ្លើយបានទេ នៅក្នុងដំណាក់កាលនេះ។ តើបញ្ហាអី? នៅពេលនោះ គឺយើងមានការពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្ម ដោយសារសក្ខីកម្មហ្នឹង គឺមេធាវីរបស់ជនជាប់ចោទទាំងពីរ គាត់ថាគាត់មិនអាចឆ្លើយបានទេនៅពេលកិច្ចប្រជុំកាលពីថ្ងៃសុក្រអាទិត្យមុន។

[១១:៤៦:៤៩]

ដូច្នេះ ដើម្បីបញ្ជាក់មួយទៀតផងដែរ នៅក្នុងអនុស្សរណៈមួយដែរ នៅមុនកិច្ចប្រជុំនេះ គឺថាវាជាការចាំបាច់ ដោយសារចៅក្រម លោក លោកស្រីចៅក្រមទាំងអស់យល់ថាវាជាការចាំបាច់ ប្រសិនបើជនជាប់ចោទអាចនឹងត្រូវឆ្លើយនូវសំណួរផ្សេងៗ នៅដំណាក់កាលនៅសវនាការទាក់ទងនឹងការពិនិត្យទៅលើភស្តុតាង ហើយនិងដែលនឹងចាប់ផ្តើមនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១នេះ។ ដូច្នេះដើម្បីជួយក្នុងការរៀបចំ និងដំណើរការឲ្យបានកាន់តែប្រសើរនៅពេលខាងមុខនេះ។ ដោយសារមានការកត់សម្គាល់ទៅលើបីចំណុច គឺទីមួយ គឺពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន គាត់បាននិយាយនៅថ្ងៃនេះ គាត់ថានឹងចូលរួមក្នុងដំណើរការនីតិវិធីតុលាការ ហើយដូច្នេះយើងអាចសន្មតថា គាត់នឹងអាចផ្តល់សក្ខីកម្ម និងឆ្លើយនឹងសំណួរផ្សេងៗបាន។

[១១:៤៧:៣៨]

ទីពីរ ទាក់ទងទៅនឹងការកត់សម្គាល់ ទីពីរគឺទាក់ទងនឹងលោក អៀង សារី ដែលបានលើកឡើងក្នុងមតិមួយថា គាត់នឹងមិនចូលរួម ប៉ុន្តែនៅក្នុងមតិមួយទៀត នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ហ្នឹងថា គាត់អាចនឹងចូលរួម។ យើងដឹងថាកាលពីលើកមុនមេធាវីការពារក្តីបានលើកឡើងថា លោក អៀង សារី នឹងមិនចូលរួមក្នុងការផ្តល់សក្ខីកម្មទេ។ ដូច្នេះឃើញថា ចម្លើយរបស់គាត់គឺនៅមានភាពមិនច្បាស់លាស់។

ទាក់ទងនឹងចំណុចទីបី ទាក់ទងទៅនឹងលោក នួន ជា នៅតែមិនមានការសម្រេចនោះច្បាស់លាស់ដែរ។ ដូច្នេះនៅក្នុងកង្វះខាតនៃការបញ្ជាក់នេះ ជាពិសេសទាក់ទងទៅនឹងលោក អៀង សារី យើង

សួរថាតើជនជាប់ចោទទាំងអស់ ត្រូវបានសួរថាតើគាត់នឹងផ្តល់សក្ខីកម្មក្នុងពេលមួយសប្តាហ៍កន្លះខាងមុននេះទៀតដែរឬទេ? ហើយដើម្បីឱ្យកិច្ចដំណើរការប្រព្រឹត្តដោយរលូន និងមានការរៀបចំដោយមានប្រសិទ្ធភាពហ្នឹងគួរលោក លោកស្រីចៅក្រមហ្នឹង គួរសួរបញ្ជាក់អំពីជំហររបស់ជនជាប់ចោទទាំងបី ហើយនិងមេធាវីការពារក្តីទាំងបីឱ្យបានច្បាស់លាស់ ដើម្បីជាការរៀបចំដំណើរការនៅពេលខាងមុខនេះឱ្យកាន់តែប្រសើរឡើង។

[១១:៤៨:៤៥]

ហើយចំពោះសហព្រះរាជអាជ្ញានឹងផ្តល់សក្ខីកម្មទាំងអស់នៅពេលសវនាការ នៅអង្គសេចក្តីខាងមុខ នូវអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងរបស់ខ្លួន ក្នុងងពេលសន្និដ្ឋានបើកការចោទប្រកាន់នេះ ហើយទុកឱ្យអង្គជំនុំជម្រះជាអ្នកសម្រេចនៅលើបញ្ហាទាំងនេះ។

ចា៎ស សូមអរគុណ សូមបញ្ជាក់បន្ថែម។

**ប្រធានអង្គជំនុំ៖**

លោក ពេជ អង្គ មានអ្វីចង់ពាក់ព័ន្ធនឹងបញ្ហានេះទេ?

សូមអញ្ជើញលោកខាងការពារក្តី តើមានមតិយោបល់អ្វីទេលើ ពាក់ព័ន្ធនឹងការដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ។

[១១:៤៩:៤១]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម សហការីខ្ញុំ និងអ្នកចូលរួមទាំងអស់។ ខ្ញុំមានការរន្ធត់ណាស់ ដែលសហព្រះរាជអាជ្ញាទាំងជាតិ និងអន្តរជាតិមានការយល់ច្រឡំជាមួយនឹងពាក្យថា "ចូលរួម"។ ពួកគាត់ទាំងពីរគួរណាស់តែយល់ដឹង ហើយនិងអានរដ្ឋធម្មនុញ្ញអំពីសិទ្ធិ ដែលត្រូវនិយាយ និងសិទ្ធិដែលមិនរក្សានូវភាពស្ងៀមស្ងាត់ និងសិទ្ធិចូលរួមរបស់មេធាវីការពារក្តី មានន័យថាត្រូវតែឡើងឈរនិយាយ ហើយផ្តល់ភស្តុតាងនោះទេ។ ពាក្យថា "ចូលរួម" គឺមកចូលរួមក្នុងសវនាការ មកស្តាប់ មកមើលខ្សែវីដេអូជាដើម។ល។ ហើយពាក្យថា ចូលរួមនេះ គឺជនជាប់ចោទអាចមានការពិនិត្យគ្រោះយោបល់ជាមួយនឹងមេធាវីរបស់ខ្លួន ទាក់ទងទៅនឹងដំណើរការនីតិវិធី និងសវនាការនេះ។ តាំងពីដើមមកលោក អៀង សារី បានចូលរួមជាមួយនឹងមេធាវីរបស់គាត់ ហើយគាត់បានបញ្ជាក់រួចហើយជាលាយលក្ខណ៍អក្សរថា នឹងមិនផ្តល់សក្ខីកម្មនោះទេ។ ហើយយើងបានជូនដំណឹងនេះ ទៅអង្គជំនុំជម្រះ

ម្តងរួចមកហើយ ដោយសារយើងមានបំណងចង់ជម្រាបជូនឲ្យបានដឹងតាំងពីដើមទី ដើម្បីរៀបកម្មវិធីសវនាការ ដែលថាយ៉ាងហោចណាស់នៅក្នុងដំណាក់កាលនេះ ផ្នែកនៃសវនាការនេះថា ជនជាប់ចោទណាដែលមានបំណងចង់ផ្តល់សក្ខីកម្ម ហើយជាសាក្សីដំបូងគេ ជាសាក្សីទីមួយ។ ហេតុនេះជាបានជាយើងបានជូនដំណឹងទៅលោក លោកស្រីចៅក្រម ដើម្បីឲ្យរៀបចំតារាងកម្មវិធីសម្រាប់សវនាការ។

[១១:៥១:៣៥]

ខ្ញុំមិនអាចនិយាយជំនួសពួកគាត់ ដោយថាគឺថាគាត់មិនអាចផ្តល់សក្ខីកម្មបាននោះទេ។ ហើយដូច្នេះយើងត្រូវធានា ថាតើសាក្សីទាំងអស់ត្រូវតែត្រៀមរួចជាស្រេចមុននឹងចូលទៅដល់ដំណាក់កាលនោះ។ នេះសម្រាប់ជាការបង្កលក្ខណៈងាយស្រួលទេ។ អ៊ីចឹងសូមជម្រាបជូនដល់សហព្រះរាជអាជ្ញាទាំងពីររូបថា ហាក់បីដូចជាមានការយល់ច្រឡំទៅលើពាក្យថា “ចូលរួម”។ តើពាក្យ “ចូលរួម” មានន័យដូចម្តេចនោះ? លោក អៀង សារី នឹងបន្តចូលរួម នឹងជួយទៅដល់មេធាវីការពារក្តីរបស់គាត់ ហើយគាត់នឹងមិនផ្តល់សក្ខីកម្មទេ។ គាត់នេះ គាត់អនុវត្តសិទ្ធិគាត់ស្របច្បាប់ទៅនេះ។ ខ្ញុំមិនអាចនិយាយជំនួសឲ្យជនជាប់ចោទដទៃទៀតបានទេ។ សូមអរគុណច្រើន។

[១១:៥២:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ក្រុមមេធាវីដទៃទៀតមានមតិយោបល់អ្វីទេ? ពាក់ព័ន្ធនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនដឹងថា ខ្ញុំមានរយៈពេលប៉ុន្មានទេ ប៉ុន្តែខ្ញុំនៅតែមានចម្លើយតបទៅនឹងការផ្តើមបើកការចោទប្រកាន់។ តាម--

[១១:៥២:៥៥]

**ប្រធានអង្គជំនុំ៖**

អំមិញនេះយើងប្រាប់លោកហើយថា បញ្ហាដែលលោកអាចធ្វើការតបនេះ គឺអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ជុំវិញបញ្ហានៃការសួរបញ្ជាក់នូវការអនុវត្តសិទ្ធិក្នុងឆ្លើយផ្តល់សក្ខីកម្ម ឬក៏មិនផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ ដែលជាកូនក្តីរបស់លោក។ ពុំមែនរឿងដដែលទេ រឿងអ្វីដែលបានអង្គជំនុំជម្រះបានសម្រេចរួចហើយ គឺមិនអនុញ្ញាតឲ្យលើកយកមកដដែលៗនោះឡើយ។

សួរ សំណួរសួរ ថាតើលោកមានអ្វីដែលពាក់ព័ន្ធទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាជាតិដែលបានលើកឡើងអម្បាញ់មិញនេះ? ពាក់ព័ន្ធជាមួយនឹងការរៀបចំ នៅក្នុងការសួរដេញដោលភស្តុតាង ដែលនឹងចាប់ផ្តើមចាប់ពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ជុំវិញបញ្ហាថា កូនក្តីរបស់លោកឆ្លើយ ឬក៏រក្សាសិទ្ធិមិនឆ្លើយតបនឹងសំណួរទាំងឡាយដែលនឹងចោទសួរនៅក្នុងសវនាការ ដើម្បីសម្រួលដល់ការរៀបចំកិច្ចដំណើរការកម្មវិធីពិភាក្សាដេញដោលចាប់ពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ តទៅ។

[១១:៥៤:២៥]

បញ្ហាផ្សេងទៀតអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកនិយាយឡើយនាពេលនេះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ វាជាការ វាជាផលប្រយោជន៍ណាស់ ខ្ញុំមិនទាក់ទងទៅនឹងកម្មវិធីពេលវេលាទេ។ អ្វីដែលខ្ញុំចង់និយាយសម្រាប់កូនក្តីរបស់ខ្ញុំ គឺគាត់មានចេតនាឆ្លើយទៅនឹងសហព្រះរាជអាជ្ញា។ អ៊ីចឹងសូមជូនដំណឹងថា កូនក្តីខ្ញុំមានចេតនាឆ្លើយ។

**ប្រធានអង្គជំនុំ៖**

អរគុណ។

ចៅក្រមមេធាវី ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមជម្រាបក្រុមប្រឹក្សាជំនុំជម្រះ លោក ខៀវ សំផន នឹងឆ្លើយនូវសំណួរ បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការផ្តល់ព័ត៌មាននេះ។ យ៉ាងម៉េចទៅ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

*(គ្មានការបកប្រែ)*

**លោក ខៀវ សំផន៖**

ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា នៅពេលសវនាការខាងក្រោយនេះ ខ្ញុំមិនទាន់ឆ្លើយ ខ្ញុំសូមបញ្ជាក់ថាខ្ញុំមិនទាន់ឆ្លើយ។ ខ្ញុំចង់ស្តាប់លោកព្រះរាជអាជ្ញាសិន ប៉ុន្តែខ្ញុំនឹងឆ្លើយនៅពេលដែលសមស្រប។ ពីព្រោះលោកព្រះរាជអាជ្ញាជាអ្នកផ្តល់ភស្តុតាង មិនមែនខ្ញុំអ្នកដែលត្រូវផ្តល់ភស្តុតាងអំពីអំពើស្មោះត្រង់របស់ខ្ញុំទេ។ លោកព្រះរាជអាជ្ញាចង់ចោទអីខ្ញុំ បង្ហាញឲ្យច្បាស់សិនមក ខ្ញុំចាំមើលឲ្យអស់សិន។ ដល់រួចពីហ្នឹង

ទៅ ខ្ញុំឆ្លើយហើយ ហ្នឹងខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេ។ សូមអរគុណ។

[១១:៥៦:៣១]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សូមអញ្ជើញ សហមេធាវីនាំមុខ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ យើងចង់ដឹងពីគោលជំហររបស់ខាងការពារក្តី ដើម្បីបង្ហាញពីគោលជំហររបស់យើង។ ប្រសិនបើការនៅស្ងៀមជាសិទ្ធិរបស់ជនជាប់ចោទនោះ ខ្ញុំគិតថាដើមបណ្តឹងរដ្ឋប្បវេណី គឺគិតថា ដើម្បីជាការគោរពដល់ជនដែលបានចូលរួមនៅក្នុងសវនាការនេះ ហើយនិងដែលជាការគោរពដល់អ្នកដែលសាធារណជនទាំងអស់នោះ គឺថា-- ហើយក៏ជាការគោរពទៅដល់ជនរងគ្រោះ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ គឺថាយ៉ាងហោចណាស់ បើមិននិយាយ ក៏សុំឱ្យផ្តល់ការពន្យល់ផង។ ហើយនៅពេលគេសុំអីមួយ សុំឱ្យគាត់ផ្តល់ការពន្យល់តិចតួច ពីព្រោះថាវាជាការចាំបាច់ណាស់សម្រាប់យើងទាំងអស់គ្នា ដើម្បីឱ្យយើងឃើញការពិត។ វាជាប្រការល្អ។

[១១:៥៧:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និងអង្គជំនុំជម្រះទាំងអស់! ក្នុងឱកាសនៃពេលពិនិត្យទៅលើជនជាប់ចោទ ហើយនិងសាក្សីដើម្បបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ដូចលោកស្រីអេលីហ្សាបេត បានជម្រាបហើយ វាចាំបាច់ណាស់។ ចាំបាច់ដែលថា ជនជាប់ចោទត្រូវតែធ្វើការឆ្លើយនេះគឺជាពេលវេលាសមស្របដែលត្រូវឆ្លើយ ហើយដែលដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះទាំងអស់ កំពុងចាំថា តើអ្នកដែលជាជនជាប់ចោទនោះ មានអ្វីដែលនឹងត្រូវនិយាយ? ហើយនេះ គឺមានសារៈសំខាន់សសម្រាប់ជនរងគ្រោះទាំងអស់គ្នា។ ហើយប្រសិនបើមិនមាន-- មិននិយាយទេ ហាក់ដូចជាចង់បង្ហាញថា ខ្លួនឯងហ្នឹង បានទទួលខុស។ អ៊ីចឹង គួរតែនិយាយ ហើយជាការពិត នេះគឺសិទ្ធិរបស់ជនជាប់ចោទ ជាការពិត។ ក៏ប៉ុន្តែទន្ទឹមនឹងការរង់ចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរតែនិយាយ។ សូមអរគុណ។

[១១:៥៨:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសេចក្ដីត្រេកអរណាស់ សូមធ្វើការកត់សម្គាល់ដូចខាងក្រោម៖

វាហាក់បីដូចថាមានការយល់ច្រឡំគ្នាយ៉ាងខ្លាំង រវាងមេធាវីជាតិ-- ការពារក្ដីជាតិ និងអន្តរជាតិទាក់ទងទៅនឹងសិទ្ធិរបស់កូនក្ដីរបស់យើង។ សិទ្ធិទាំងអស់នេះវាមិនស្មើគ្នាទេ អ្នកណាគាត់ចង់នៅស្ងៀមក៏នៅស្ងៀមទៅ មិនចាំបាច់ត្រូវការពន្យល់អីទេ ថាតើទោះបីជានៅក្នុងតុលាការជាតិក្ដី ក្នុងតុលាការអន្តរជាតិក្ដី អ៊ីចឹងខ្ញុំថាគួរមានការយល់ដឹងឲ្យបានច្បាស់ចំពោះមេធាវីទាំងពីររបស់ក្រុមនេះ។ ខ្ញុំមិនដឹងថា តើគាត់ការពារកូនក្ដីរបស់គាត់មានប្រសិទ្ធភាពដោយរបៀបណាទេ? បើឡើងឈរហើយ ស្រាប់តែនិយាយច្បាប់ទាំងមិនច្បាស់លាស់ដូច្នេះ។

[១១:៥៩:៤២]

ការនៅស្ងៀមមិននិយាយស្ដី មិនមែនថាមានពិរុទ្ធភាពទេ។ ហើយខ្ញុំយល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដល់ឱកាសឲ្យធ្វើសេចក្ដីបើកនោះទេ។ ហើយនៅក្នុងសេចក្ដីបើកការចោទប្រកាន់នេះជាពិសេសនៅក្នុងយុត្តាធិការរបស់តុលាការនេះជាជាងតុលាការដទៃ។ ឥឡូវនេះ គឺគេបានទទួលឱកាសផ្សេងៗដើម្បីធ្វើសេចក្ដីថ្លែងជាសាធារណៈ ដើម្បីជាការសន្និដ្ឋានជាសាធារណៈ ដើម្បីតម្រូវចិត្តទៅដល់អ្នកដែលចូលរួម ចាត់ទុកថាគាត់ដឹងច្បាប់ទៅចុះ។ គាត់ដឹងថា ជនជាប់ចោទមានសិទ្ធិ មិននិយាយស្ដីនៅស្ងៀម ហើយព្រះរាជអាជ្ញាជាអ្នកធ្វើសេចក្ដីផ្ដើមការចោទប្រកាន់។

ហើយឥឡូវនេះ គឺជាពេលវេលាដែលតុលាការត្រូវបង្ហាញបន្ទុកនៃភស្តុតាង ហើយយើងនឹងបញ្ជាក់អះអាងទៅតាមនោះ មិនត្រូវការអ្វីដែលត្រូវឲ្យខ្ញុំ ដែលត្រូវបញ្ជាក់នោះទេ។ ប៉ុន្តែលោកប្រធាន លោក លោកស្រីចៅក្រម ប្រសិនណាជានៅក្នុងពេលអនាគត មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានសម្ដែងមតិណាមួយឲ្យបានសមស្របទេ។ ឧទាហរណ៍ថា នៅពេលដែលអ្នកណាម្នាក់នៅស្ងៀមស្ងាត់នោះ មានន័យថាការនៅស្ងៀមស្ងាត់របស់ជនជាប់ចោទ មានន័យថាជនជាប់ចោទមានពិរុទ្ធភាពមិនត្រឹមត្រូវទេ។

[១២:០១:១១]

ដូច្នេះ សហការីរបស់ខ្ញុំដែលបានមកពីប្រទេសដែលទទួលការបណ្តុះបណ្តាលផ្នែកច្បាប់យ៉ាងប្រត្យក្សនោះ គឺគាត់នឹងបានដឹង។ ខ្ញុំសូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យតតាំងទេ គ្រាន់តែស្តាប់មតិយោបល់ប៉ុណ្ណោះ។ ហើយមេធាវីក៏មិនគប្បីការប្រើពាក្យពេចន៍អ្វី ដែលជាការព្រមានដល់អ្នកដទៃផងដែរ។ នេះជាលើកដំបូងហើយ ហើយលើកក្រោយគឺមិនអនុញ្ញាតឲ្យនិយាយដូច្នេះទេ។

ឥឡូវនេះ អង្គជំនុំជម្រះសរុបមកវិញ គឺសូមជម្រាបជូនដល់ភាគីឲ្យបានជ្រាបថា ទាំងការគម្រោងផែនការក្នុងការរៀបចំនៅក្នុងកិច្ចដំណើរការដេញដោលភស្តុតាង ដែលអង្គជំនុំជម្រះ បានប្រជុំពិភាក្សាដោះស្រាយបញ្ហានេះច្រើនលើកច្រើនសាមកហើយ ហើយការប្រមើលមើលនូវបញ្ហាដែលអាចកើតមាននៅក្នុងអំឡុងពេលនៃការពិនិត្យដេញដោលភស្តុតាង ចាប់ផ្តើមពីការស្តាប់នូវចម្លើយជនជាប់ចោទទៅ គឺយើងគ្រោងទាំងការ ជនជាប់ចោទឆ្លើយ ជាទូទៅចំពោះអង្គហេតុទាំងឡាយដែលអង្គជំនុំជម្រះលើកមកដាក់សម្រាប់សួរដេញដោលនៅក្នុងវគ្គនីមួយៗ នៃកិច្ចដំណើរការ គ្រោងទាំងគិតថា មានជនជាប់ចោទខ្លះអាច រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបចំពោះអង្គហេតុខ្លះៗ ឬក៏កថាខណ្ឌខ្លះ តែគាត់រក្សា និងមានសិទ្ធិនៅក្នុងការឆ្លើយតបចំពោះកថាខណ្ឌផ្សេង ដែលជាបន្ទុកចោទប្រកាន់លើគាត់។ នេះជាសិទ្ធិ យើងនឹងប្រឹងប្រែងគ្រប់គ្រង នូវកិច្ចដំណើរការរបៀបនេះឲ្យបានល្អប្រសើរ។

[១២:០៣:០៥]

បញ្ហាដទៃទៀត ទំនងជាភាគីបានយល់ជ្រាបហើយ ថាហេតុអ្វីបានជាអង្គជំនុំជម្រះមិនបន្តធ្វើសវនាការដេញដោលពិនិត្យភស្តុតាង តាមកាលវេលាដែលបានគ្រោងទុកនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ បែរជាលើកដំណើរការនៃសវនាការពិនិត្យដេញដោលភស្តុតាងរហូតដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ទៅវិញ គឺទំនងជាដោយសារមូលហេតុទាំងអស់នេះហើយ ក្នុងការរៀបចំចាត់ចែង ដើម្បីគ្រប់គ្រងសម្របសម្រួលដឹកនាំកិច្ចពិភាក្សាដេញដោលភស្តុតាង ធ្វើយ៉ាងណាឲ្យប្រព្រឹត្តទៅដោយរលូន និងប្រសិទ្ធភាពបំផុត។ ទោះបីការប៉ាន់ស្មាន និងការប្រមើលមើលរបស់អង្គជំនុំជម្រះ គិតថាបញ្ហានេះវាស្មុគស្មាញក៏ដោយ ក៏ខ្លួននៅតែប្រឹងប្រែងពិនិត្យពិចារណា និងរកមធ្យោបាយសមស្របបំផុតដើម្បីដោះស្រាយបញ្ហានេះ។ ហើយជាបន្តបន្ទាប់គឺ អង្គជំនុំជម្រះបានចេញជាបណ្តើរៗនូវអនុស្សរណៈ ដើម្បី

ជម្រាបជូនទៅភាគីដែលពាក់ព័ន្ធ ដើម្បីផ្តល់នូវការសិទ្ធិរបស់ខ្លួន ឬក៏ភារកិច្ចរបស់ខ្លួន នៅក្នុងការតាំងសំណួរផ្សេងៗ ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ឬអ្នកជំនាញដែលខ្លួនដាក់។

[១២:០៤:៤៤]

ហើយអង្គជំនុំជម្រះមិនទាន់បានអះអាងថា តើប្រាប់ភាគីថាដូចម្តេចឲ្យត្រូវនោះទេ ទំហំរឿងក្តីនេះ។ ឧទាហរណ៍ថា សួរដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ តើចំណាយពេលវេលាប៉ុន្មាន? ពីព្រោះការដឹងវាខុសគ្នា។ អង្គហេតុធំធេងជាង១៥០០កថាខណ្ឌចោទប្រកាន់ អង្គហេតុទូទាំងប្រទេស វិសាលភាពធំធេងដូច្នេះតើសាក្សីហ្នឹងវាដឹងប៉ុនណា? អ្នកជំនាញដឹងកម្រិតណា? យើងប្រមាណប្រមើលមើលកម្រិតណា? ដើម្បីគ្រប់គ្រង ដើម្បីបែងចែកពេលវេលាឲ្យភាគីមានឱកាសក្នុងការសួរដេញដោលសមស្រប ដែលអាចទទួលយកបានដោយមិនចំណាយពេលវេលាខ្ជះខ្ជាយ ដែលនាំឲ្យដំណើរការសវនាការនេះ អូសបន្លាយដែលនឹងប៉ះពាល់ទៅដល់គោលការណ៍ នៃការគោរពការស្វែងរកយុត្តិធម៌ដោយឆាប់រហ័ស។

[១២:០៥:៤៥]

ដូច្នេះ គឺជាសរុបមកវិញចំពោះសំណួរដែលលោកជំទាវបានសួរ គឺខ្ញុំសូមជម្រាបថា សូមត្រៀមលក្ខណៈគ្រប់សព្វតាមផែនការ និងតាមអ្វីដែលអាចប្រព្រឹត្តទៅដោយប្រក្រតីភាព ក្នុងករណីដែលរៀបចំហើយ បែរជាមិនមានបញ្ហានោះកើតឡើង យើងគិតថា វាទំនងជាអត់មានបញ្ហាអីទេ។ ផ្ទុយទៅវិញបើសិនបើយើងមិនគ្រោង មិនរៀបចំនូវកិច្ចការរបស់យើងទេ ស្រាប់តែកើតបញ្ហានោះកើតឡើងនៅចំពោះមុខភ្លាម រឿងក្តីដ៏ធំធេងស្មុគស្មាញរបៀបនេះ សូម្បីតែគ្រប់គ្រងនូវផ្នែកណាមួយនៃបទចោទប្រកាន់ជាក់លាក់ហ្នឹង ក៏ប្រហែលជាក្តាប់មិនបានផង រឿងក្តីរហូតដល់ទៅកន្លះលានទំព័រទៅហើយវាធំធេង។ ដូច្នេះវាមិនមែនជាការងាយនោះទេ។

[១២:០៦:៣៧]

អង្គជំនុំជម្រះសង្ឃឹមថា ភាគី ជាពិសេសតំណាងសហព្រះរាជអាជ្ញា នឹងយល់បានអំពីបញ្ហានេះ ហើយជាបន្តបន្ទាប់អង្គជំនុំជម្រះនឹងប្រឹងប្រែង ដើម្បីជម្រាបជូន និងផ្តល់ព័ត៌មានជាបន្តបន្ទាប់ដើម្បីក្នុងគំនិតឲ្យកិច្ចដំណើរការប្រព្រឹត្តទៅបានល្អប្រសើរ ហើយកាលៈទេសៈចំពោះមុខនេះ អង្គជំនុំជម្រះបានត្រៀមលក្ខណៈសម្បត្តិសមល្មម ដែលអាចថា មិនឲ្យដំណើរការសវនាការចាប់ផ្តើមពីថ្ងៃ៥នុំង មានការរអាក់រអួលរហូតដល់ផ្អាក ឬក៏ឈប់ដោយសារមូលហេតុផ្សេងៗនោះទេ។ យើងបានគ្រោងសព្វគ្រប់

អស់ហើយ ទោះបីយើងលះបង់នូវពេលវេលា ឬក៏ធនធានថវិកាខ្លះក៏ដោយ ក៏យើងបានជម្រាបជូនទៅដល់អង្គភាពពាក់ព័ន្ធឲ្យគ្រោងធ្វើផែនការនេះរួចហើយ។

[១២:០៧:២៤]

ខ្ញុំគិតថា ការបកស្រាយប៉ុណ្ណេះ គឺអាចសមល្មម និងអាចស្តាប់បានហើយ។ ឥឡូវនេះដល់ពេល-- ពេលនេះកិច្ចដំណើរការនីតិវិធីស្តាប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ចំពោះជនជាប់ចោទដោយសង្ខេបដោយសហព្រះរាជអាជ្ញា និងការឆ្លើយតបដោយសង្ខេបដោយជនជាប់ចោទ ឬ/និងមេធាវីការពារក្តីបានដល់ទីបញ្ចប់ហើយ។ ហើយក៏ដល់ពេលសមល្មមនឹងត្រូវសម្រាកហើយដែរ សម្រាប់សវនាការថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាក កិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ សវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាង អង្គជំនុំជម្រះលើកទៅបន្តធ្វើចាប់ពីថ្ងៃចន្ទ ទី៥ ខែធ្នូ ឆ្នាំ ២០១១ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សូមភាគីនិងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមនៅក្នុងសវនាការនោះឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ហើយសូមអញ្ជើញសម្រាក។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំខ្លួនជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទ ទី៥ ខែធ្នូ ឆ្នាំ២០១១ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់៕

[១២:០៨:៤០]

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១២:០៩ នាទី)*